
ពាក្យសំដីមាស
LES PAROLES D'OR
ពាក្យសំដីមាស
LES PAROLES D'OR
សៀវភៅអប់រំ ចរិយា
សៀវភៅអប់រំ ចរិយា

# យោបល់អ្នករៀបរៀង

មុននឹងសម្រេចចិត្តជ្រើសរើសសៀវភៅដែលមានតម្លៃ យកទៅទុកក្នុងទូ មិត្តអ្នកអានគួរបានពិចារណាដល់គំនិតនេះផង ។

(ឱ! បុព្វបុរសជាតិ មកដល់ថ្ងៃនេះ លោកមិនបានដឹងមិនបានយល់ កូនចៅខាងក្រោយសព្វថ្ងៃនេះ ។ រូបរាងកូនចៅខាងក្រោយនេះ ដែលរស់សព្វថ្ងៃ មានភាពប្លែកពីបុរាណច្រើនណាស់។ បណ្ដាផ្ទះសម្បែងប្រក់ស្លឹកប្រក់ស្បូវបានប្រែក្លាយទៅជាផ្ទាំងស៊ីម៉ងត៍ មានសរសៃដែក ស្ពានដានជើងក្របី នៅលើវាលស្រែចម្ការ បានរលាយបាត់អស់ទៅដោយរណ្ដៅ។ គ្រាប់បែក គ្រាប់កាំភ្លើង ក្នុងសម័យសង្គ្រាម។ បណ្ដាលលក្ខណៈផ្សេងៗនៃសម័យដើម បានប្រែក្លាយសន្ធឹកសន្ធាប់ណាស់... ស្ទើរតែចង់និយាយថា គ្មានអ្វីដែលមានចរិកពីមុនមកទៀតទាំងអស់ ។

ប៉ុន្តែមិនមែនដូច្នោះទេ សូមជំរាបបុព្វបុរសទាំងអស់ បណ្ដាការប្រែប្រួលពីចាស់មកថ្មីទាំងនេះ គឺជាស្លាកស្នាមនៃពេលវេលាបង្ហាញឱ្យឃើញថាជាតិមួយកំពុងតែលូតលាស់ ប្រជែងគ្នានៅក្នុងសាកលលោកដែរ។ ដំណក់ឈាមរបស់បុព្វបុរសកំពុងតែរត់ចុះឡើងនៅក្នុងសរសៃឈាម របស់កូនចៅថ្ងៃក្រោយ។ បណ្ដាពាក្យចម្រៀងបំពេរកូន នៅក្រោមដំបូលផ្ទះស្លឹក បណ្ដាពាក្យចម្រៀងអាយៃប្រកកៃនៅក្រោមពន្លឺព្រះចន្ទពេញបូរណ៍មីពីបុរាណតែងមករំលឹកកូនចៅទាំងអស់គ្នាឱ្យនឹកឃើញ នៅស្មារតីជាតិ។

នៃមិត្តក្មេងៗសព្វថ្ងៃ! បណ្ដាស្រទាប់មនុស្សជំនាន់ក្រោយនេះ ទៅថ្ងៃណាមួយមិត្តអាចមិនស្គាល់ជំនាងផ្ទះ មិនដឹងជំនាងផ្ទះមានរូបរាងយ៉ាងណាទេ ពីព្រោះទៅថ្ងៃមុនមិត្តនៅក្នុងវីឡាផ្ទះថ្មី ផ្ទះតជួរអស់ទៅហើយ មិត្តនឹងមិនដឹងគេបុកឬកិនស្រូវយ៉ាងណាទេ ពីព្រោះមិត្តមានម៉ាស៊ីនមកធ្វើការជំនួស ដែលពីដើមមកបុរសយើងធ្វើការដោយលំបាក។ ប៉ុន្តែមិត្តត្រូវយល់ថា មិត្តមិនអាចចាកផុតពីលក្ខណៈរបស់ជាតិបានទេ។

ពាក្យដ៏ពីរោះៗនៅក្នុងសៀវភៅនេះ គឺជាពាក្យសម្ដីឬជាគំនិត របស់បុព្វបុរសយើងគេនៅក្នុងពិភពលោក។ យើងកុំស្មានថាសម័យឥឡូវនេះ មានការប្រែប្រួលច្រើនខាងសម្ភារៈ ប៉ុន្តែសម័យបុរាណ បុព្វបុរសយើងក៏មានគំនិតថ្មីៗច្រើនណាស់ដែរ

ដែលកន្លងច្រើនឆ្នាំមកហើយក៏នៅតែថ្មីដដែល ។

ហេតុដូច្នេះកូនសៀវភៅនេះ មិត្តគួរជ្រើសរើសទុកក្នុងទូគ្រួសារ ដើម្បីជាអនុស្សាវរីយ៍ដល់បុព្វបុរសយើង ដែលបានគិតគូរទុកឱ្យយើងផ្នែកខាងគំនិត) ។

★ ★ ★

ពាំងល្វា ថ្ងៃ ១៧ ៦ ១៩៧៣

**ហ៊ុន គីមស៊ា**

# វាចាអ្នកចម្លង

ខ្ញុំព្រះករុណាខ្ញុំបាទ ថៃ ប៊ុនឆាយ សូមថ្វាយបង្គំព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃជាទីពឹងស្មើដោយជីវិត ។ ដោយសេចក្ដីជ្រះថ្លា ខ្ញុំព្រះករុណាក៏បានព្យាយាមវាយចម្លងធ្វើជា E-BOOK ដើម្បីងាយស្រួលក្នុងការទាញយក (Download) ក្នុងប្រព័ន្ធ (Internet) ខ្ញុំព្រះករុណាក៏សូមឧទ្ទិសបុណ្យកុសលដែលកើតមានដោយការព្យាយាមនេះ ដល់លោកអ្នកមានគុណទាំងពីររបស់ខ្ញុំបាទ និងសូមជូនដល់មិត្តភក្ដិទាំងគ្នាសូមអនុមោទនា !!!

ភ្នំពេញ
ថ្ងៃទី ២៤ ខែ ធ្នូ ព.ស. ២៥៥៧
**ថៃ ប៊ុនឆាយ**

ពិនិត្យអក្ខរាវិរុទ្ធ
**ថៃ ប៊ុនឆាយ**

# សម្តីមាស

១- ត្រូវខំហាត់ហ្វឹកហ្វឺនចរិយាមនុស្សឱ្យដល់ខ្លួនយើងនឹងមនុស្សដែលនៅជុំវិញយើង ដើម្បីបង្ហាញនូវការដឹងគុណឱ្យដល់មនុស្សពីមុនៗមក ដែលបានបង្កើតយើង។

ADDISON

២- មិត្តត្រូវសង្ស័យចំពោះមនុស្សដែលប្រកាសប្រាប់គេថា : ត្រូវតែកែប្រែភាសាឱ្យបានល្អឡើង។ ការពិតគឺគេរកមធ្យោបាយបង្កើតជាមួយនឹងពាក្យសម្តី តែលទ្ធផលវិញ គឺគេមិនចេះបង្កើតជាមួយនឹងគំនិតគេឡើយ។

AUGUSTIN

៣- មិត្តកុំស្មានថា : មនុស្សយើងដល់ពេលស្លាប់ទើបដាក់ទានធ្វើអំណោយដល់គេ បើនិយាយឱ្យចំទៅ មនុស្សស្លូឈាមជិតស្លាប់ទៅហើយយកទ្រព្យគេមកធ្វើអំណោយជាជាងយកទ្រព្យផ្ទាល់ខ្លួនឯង។

BACON

៤- សេចក្តីកំណាញ់របស់ឪពុកម្តាយចំពោះកូនចៅ គឺជាកំហុសមួយដែលមិនអាចអត់ឱនបាន។ កំហុសនោះវានាំឱ្យកូនអស់សង្ឃឹម នាំឱ្យកូនអស់តម្លៃ នាំឱ្យកូនចេះបោកប្រាស់ នាំឱ្យកូនចងមិត្តភក្តិនឹងមនុស្សអាក្រក់ៗ កាលណាកូនធំឡើងមានលុយកាក់ វាទៅអាវាសែស៊ីចាយផ្តេសផ្តាសខុសខ្នាត ទៅជាបំផ្លាញទ្រព្យសម្បត្តិ។ ក្នុងរឿងនេះ អាកប្បកិរិយារបស់ឪពុកម្តាយចំពោះកូនត្រូវប្រយ័ត្នមែនទែន ត្រូវរក្សាអំណាចឱ្យបាន ជាជាងរក្សាលុយ។ BACON

៥- គឺផលប្រយោជន៍តូចតាចនេះហើយ ដែលវានាំឱ្យចង់ប្រាក់ធូន់ ពីព្រោះវាមកដល់ញឹកញាប់ ជាជាងផលប្រយោជន៍ធំដែលវាកម្រមកដល់។

៦- នៅក្នុងករណីខ្លះនៃជីវិតមនុស្ស គេអាចទ្រាំបានតែមិត្តសំឡាញ់ដែលរស់នៅជិតគ្នាទេ។ ពាក្យសម្ដីលួងលោមធ្វើឱ្យដំបៅកាន់តែឈឺចាប់ថែមហើយបង្ហាញនូវការស៊ីជម្រៅថែម ។

៧- ទឹកមុខនៃមនុស្សសប្បុរសស្មោះត្រង់ មានសភាពភ្លឺថ្លាណាស់។

៨- មនុស្សយើងបន្តិចម្ដងៗ ត្រូវឱ្យមានទស្សនៈខ្ពង់ខ្ពស់ខាងការល្អនឹងការអាក្រក់។ ពីទស្សនៈនេះមក មនុស្សអាចមើលឃើញច្បាស់នូវចរិយាល្អិតល្អោច នឹង ចរិយាធំដុំ ប៉ុន្តែវាមិនអាចមានចរិយាហើយគ្មានយុត្តិធម៌ ហើយក៏មិនអាចមានយុត្តិធម៌ហើយគ្មានមេត្តាដែរ។
BATAILLE

៩- មិត្តភាពប្រៀបបាននឹងដើមឈើដែលដុះល្អជានិច្ច វាទើបតែមានផ្កាវាមានផ្លែតែម្ដង ។ JACQUES HENRI

១០- មនុស្សស្រីមិនចាំបាច់ឱ្យទៅជាអ្នកប្រាជ្ញទេ ប៉ុន្តែបើតាមយោបល់ខ្ញុំវាបែបដូចជាមិនទាន់គ្រប់គ្រាន់ បើគ្នាមិនបានបើកខួរក្បាលធំ ប្រកបដោយការរំភើបចិត្តខ្ពង់ខ្ពស់ស្អាតបានខាងសិល្បៈ សិល្បៈគឺជាការបន្ថែមឱ្យគ្រប់ដល់ ជីវភាពខ្ពង់ខ្ពស់ដូចគ្នានឹងកិត្តិយសគឺជាការបន្ថែមឱ្យគ្រប់ដល់ក្រមច្បាប់ ។ BOURGET

១១- មនុស្សយើងស្មើរតែទាំងអស់គ្នា កើតមកដោយសារមានជាតិពីកំណើតខ្លះ ហេតុនេះបានជាមានស្លាកស្នាមនៅមុខមាត់។

SAVARIN

១២- យើងត្រូវយកចិត្តទុកដាក់សម្លឹងមើលមនុស្សដែលកំពុងតែខំប្រឹងធ្វើការដោយស្ងាត់ស្ងៀម លាតត្រដាងអស់នូវថាមពលរបស់ខ្លួន។ មកអំពីអាកប្បកិរិយាវិរបុរស ដោយស្ងាត់ស្ងៀមនឹងអាថ៌កំបាំងនេះហើយ ដែលសាកលលោកចេះតែដើរទៅមុខនឹងធរមានបាន ។

BRULAT

១៣- យើងទាំងអស់គ្នាគប្បីប្ដេជ្ញាចិត្តថា : មុននឹងបំពេញកិច្ចការអ្វីឱ្យសព្វគ្រប់ទាំងអស់ គេមិនអាចបោះចោលករណីកិច្ចរបស់យើងទេ ទោះបីករណី-យកិច្ចនោះយ៉ាងណាក៏ដោយ។

១៤- មានពេលខ្លះមនុស្សពាលក៏ធ្វើអំពើល្អដែរ : គេអាចនិយាយថា : នេះគឺជាការមួយដែលមនុស្សពាលចង់ដឹងឱ្យច្បាស់លាស់ថា : តើអំពីល្អនេះ វានាំឱ្យមនុស្សត្រេងសប្បាយចិត្តឬទេ ។

CHAMFORT

១៥- មនុស្សល្ងង់មានពេលខ្លះឆ្លាតវាងវៃនាំឱ្យគេឆ្ងល់ ហើយគេភ្ញាក់ផ្អើលដូចគ្នានឹងសេះអូសរទេះហើយផាយ ។

១៦- កាលណាគេមានគំនិតថា : បណ្ដាមនុស្សមិនសូវរំភើបចិត្តបំផុត គឺជា

មនុស្សសប្បាយចិត្តបំផុត ខ្ញុំនឹកទៅដល់ពាក្យភាសិតឥណ្ឌាថា : *(អង្គុយគ្រាន់បើជាងឈរ ដេកគ្រាន់បើជាងអង្គុយប៉ុន្តែ ស្លាប់វាគ្រាន់បើជាងរឿងអស់នេះ)* ។

**១៧-** អ្នកណាគ្មានលក្ខណៈ គឺមិនមែនជាមនុស្ស នោះគឺជាវត្ថុទៅវិញ។

**១៨-** គំនិតវាលួងលោមនឹងកែប្រែកិច្ចការទាំងអស់ មានពេលខ្លះគំនិតវាបំផ្លាញយើង មិត្តត្រូវទាមទារឧសថដើម្បីព្យាបាលការបំផ្លាញនោះ ហើយគំនិតវានឹងផ្តល់ឱ្យមិត្តបានល្អ ។

**១៩-** បណ្តាច្បាប់នៃការសម្ងាត់ នឹង ការប្រគល់ឱ្យនៃការសម្ងាត់គឺវាដូចគ្នា។

**២០-** កាលណាចង់ឱ្យគេសប្បាយចិត្ត យើងត្រូវដោះស្រាយដើម្បីឱ្យមនុស្សដែលមិនដឹងអ្វីទាំងអស់ ហើយចេះតែបង្គាប់បញ្ជាយើងនូវប្រការដែលយើងបានដឹងរួចហើយ ។

**២១-** មានប្រការពីរដែលត្រូវហ្វឹកហ្វឺនឱ្យធ្លាប់ ដើម្បីកុំឱ្យមើលឃើញនូវជីវិតដែលថាគ្មានអ្នកណាទ្រាំរួចនោះ គឺបណ្តាការបំផ្លាញនៃពេលវេលា នឹងសេចក្តីអយុត្តិធម៌របស់មនុស្ស ។

**២២-** បណ្តាចរិតខ្ពស់ហួសហេតុពេក វានាំឱ្យមនុស្សម្នាក់មិនបានស្របនិងសង្គមមនុស្ស គេមិនដែលទៅផ្សារដោយប្រាក់ទាំងណែនៗនោះទេ គេយកប្រាក់តិចតួចប៉ុណ្ណោះ។

២៣- អពមង្គលគួរឱ្យខ្លាចតែនៅពេលចាប់ផ្ដើមទេ : កាលណាត្រូវស៊ីយ សៀវដល់កម្រិតហើយ ក្នុងពេលចាកចេញពីផែនដីទៅគេប្រទះឃើញតែតំបន់សុខសាន្តភ្លឺថ្លា ។
CHATEAUBRIANT

២៤- ទោះបីគេក្បត់យើងក៏ដោយ ក៏យើងនៅតែសប្បាយរីករាយស្រួលជានិច្ច បើកាលណាយើងបានតាំងចិត្តជាអ្នកសប្បាយហើយ។

២៥- មិត្តគប្បីប្រឹងប្រែឱ្យមានគុណសម្បត្តិធំដុំ គេនឹងបោះចោលឱ្យមិត្រនូវគុណវិបត្តិ ។ CHEMIER

២៦- មិត្តកុំគប្បីបង្ហាញនូវការឆ្លាតវាងវៃ ឬ ប្រាជ្ញប្រាយឱ្យជាងមនុស្សដែលនៅជាមួយ មិត្តត្រូវទុកការចេះដឹងរបស់មិត្តជានាឡិកាមួយដាក់ក្នុងហោប៉ៅអាវផ្សេង ហើយកុំដកយកចេញមកក្រៅឬមួយឱ្យរោ គ្រាន់តែឱ្យខ្ញុំដឹងថាមាននាឡិកាបានហើយ ។
CHESTERFIELD

២៧- មិនមែនជាមនុស្សបញ្ញា ដើម្បីតែមានយោបល់ច្រើនដូចគ្នា នឹងមិនមែនជាឧត្តមសេនីល្អ ដើម្បីតែមានពលទាហានច្រើននោះទេ ។

២៨- ខ្ញុំដឹងច្បាស់ថា : ព្រលឹងនីមួយៗត្រូវទប់ទល់នឹងការសាកល្បង តស៊ូនឹងផ្ទាញ់ខ្លួនឯង ក្នុងពេលនោះហើយ អាចជួយគ្នាទៅវិញទៅមក ។
CHANNING

**២៩**- សេចក្ដីគួរសមពិតប្រាកដគឺជាការប្រុងប្រយ័ត្នជានិរន្តរដល់សេចក្ដីត្រូវការនៃមនុស្ស ដែលរស់នៅជុំវិញយើង ។

CHATAM

**៣០**- តណ្ហាមួយដ៏ពិតប្រាកដហើយឈឺចាប់គឺនៅ មេដំបែមានពឹសពុលកប់នៅក្នុងព្រលឹងយ៉ាងជ្រៅ ហើយវានឹងធ្វើឱ្យខូចនំនៃពពួកទេព្ដា ។

CHATEAU BRIAND

**៣១**- ភាពធំដុំខ្ពង់ខ្ពស់ដូចជាក្លិនក្រអូប ចំពោះមនុស្សធំដុំខ្ពង់ខ្ពស់ក្លិនក្រអូប គេមិនសូវរំភើបចិត្តទេ។

CHRISTINE DE PISAN

**៣២**- កាលណាគេប្រើមនុស្ស «**ត្រូវស្គាល់ខ្លួនឯង**» មិនមែនសម្រាប់តែបន្ទាបភាពឆ្មើងឆ្មៃរបស់គេទេ ក៏ប៉ុន្តែដើម្បីឱ្យស្គាល់នូវតម្លៃរបស់ខ្លួន។

CICERON

**៣៣**- មនុស្សដែលធ្វើឱ្យខូចខ្លួនឯងគឺ តាំងពីគេមាននៅក្នុងបេះដូងគេ នូវគំនិតមួយដែលគេបង្ខំចិត្តលាក់ទុក។

CONSTANT DE REBECQUE

**៣៤**- ការនិយាយស្ដីរួសរាយនៃមនុស្សភាគខ្លះ គឺមកអំពីការចុះចាញ់ដោយគេនៅស្ងៀមមិនបាន ។

**៣៥**- ជីវិតរស់នៅគេមិនអាចទ្រាំបានទេ បើត្រូវតែឃោគយល់ឱ្យអ្នកដទៃទាំងអស់នូវប្រការដែលគេឱ្យច្បាប់ធ្វើ ។

COURTELINE

**៣៦**- ជាការគួរឱ្យចំឡែកណាស់ ក្នុងពេលដែលមិត្តទុកឱ្យមនុស្សស្និទ្ធស្នាលនៅនឹងជណ្តើរ បើមិត្តឡើងពីជាន់ទី១ទៅជាន់ទី៥! ។

DURUY

**៣៧**- បើមនុស្សម្នាក់អាចធ្វើសន្ទរកថាមួយល្អជាងអ្នកផ្សេង ឬក៏បង្កើតនូវប្រព័ន្ធអ្វីមួយចំឡែកល្អដើម្បីចាប់កណ្តុរ ទោះអ្នកនោះនៅក្នុងព្រៃជ្រៅយ៉ាងណាក៏ដោយ ក៏គេអាចរកផ្លូវឃើញទៅដល់ផ្ទះអ្នកនោះដែរ ។

EMERSON

**៣៨**- មានមនុស្សភាគច្រើនពិបាកចិត្តដោយមតិមហាជន អំពីវត្ថុនានា តែមិនមែនមកអំពីវត្ថុនោះទេ ។

EPICTETE

**៣៩**- មិត្តគប្បីជ្រើសរករបៀបមួយដោយខ្លួនឯង សម្រាប់ធ្វើជាគន្លងច្បាប់ហើយដើរតាមឱ្យទៀងទាត់ ទោះនៅក្នុងសង្គមមនុស្ស ឬនៅតែម្នាក់ឯងក៏ដោយ ។

**៤០**- ចាប់ផ្តើមនៃគុណទាំងឡាយ គឺការស្មោះឃោបល់នឹងការប្រកែកសន្ទនា ទីបញ្ចប់គឺបានចម្រើនល្អនឹងមានខន្តី ។

៤១- មានមនុស្សច្រើនណាស់ លួងលោមខ្លួនអំពីការឈឺចាប់នៃអ្នកដទៃ ដោយការសប្បាយដែលបានទាយទុកមុននៃអារម្មណ៍នោះ ។

៤២- មានប្រភពពីនៃអំពើអាក្រក់ដែលការឆ្លាតវាងវៃ គួរបានជៀសវាងឱ្យឆ្ងាយគឺ តណ្ហាច្របល់នឹងសេចក្តីបារម្ភរេចរិល ។
DROZ

៤៣- គេអាចទៅដល់សេចក្តីសប្បាយតែដោយសារការប្រមែប្រមូលដោយយកចិត្តទុកដាក់នូវសុភមង្គលរាយរងនានា ។

៤៤- សមត្ថភាពនៃចំណង់ គឺជាដើមទុនដ៏ត្រឹមត្រូវតែមួយ ដែលគេអាចមាននៅក្នុងជីវិត។ ការពិតគ្មានអ្នកមានណាដែលគ្មានសមត្ថភាពនេះទេ។

៤៥- បណ្តាករណីយកិច្ចបានវាស់វែង ជាធម្មតាដោយសារការប្រៀបធៀបនឹងការទាក់ទងដែលវាចង់ភ្ជាប់រវាងមនុស្សនិងមនុស្ស ។

៤៦- បើវាស់កម្រិតសុភមង្គលរបស់មនុស្សទៅតាមតែចំនួន និងការសប្បាយរបស់គេនៅក្នុងជីវិត ប៉ុណ្ណោះ ក៏អាចថាជាគ្រប់គ្រាន់បានដែរ ទោះបីខុសគ្នាក៏ដោយ។ អ្នកណាមានសេចក្តីសប្បាយតិច តែការរំភើបទៅជា ខ្លាំងបំផុតគេយល់ឃើញសប្បាយសម្បើមណាស់នូវប្រការដែលអ្នកផ្សេងមើលមិនឃើញ ឬមិនដែលបានឃើញទាស់តែសោះ ចំពោះប្រការនេះ ធម្មជាតិបានធ្វើករណីយកិច្ចគ្រប់គ្រាន់ចំពោះស្ត្រីម្តាយទូទៅ ។
FONTENELLE

៤៧- វាមិនគួរទេចំពោះមនុស្សស្មោះត្រង់ ដែលច្រើននូវសំណល់មិត្តភាពចាស់ដែលផុតរលត់ទៅហើយ ដើម្បីបំពេញនូវកំហឹងដែលទើបនឹងកើតឡើងថ្មី ។
FENELON

៤៨- បណ្តាសត្រូវពិតប្រាកដដែលរស់នៅជាមួយនឹងយើង យើងគប្បីបំបាត់ឱ្យអស់ពីបេះដូង នូវសេចក្តីលោភ សេចក្តីកំណាញ់ នឹងការឈ្នានីស នោះយើងនឹងអាចស្តាបនានូវសណ្តាប់ធ្នាប់ ការសម្របសម្រួលដែលជាប្រការអាចគ្រប់គ្រងនៅក្នុងសង្គមមនុស្ស មនុស្សទាំងអស់នឹងទៅជាមិត្ត។

៤៩- បណ្តាសេចក្តីប្រាថ្នា គឺគ្រាន់តែជាពាក្យស្នើសុំ ដែលកើតឡើងពីចម្លួតរបស់មនុស្សយកទៅបង្ហាញវាសនា ប៉ុន្តែដោយសារការមិនយកចិត្តទុកដាក់ ម្ល៉ោះហើយវាសនាក៏វាមិនរស់រានទៅទៀត ។
FENELON

៥០- សេចក្តីសាទរគឺជាមនោសញ្ចេតនានៃសេចក្តីស្នេហា ហើយស្នេហាគឺជាសេចក្តីសាទរនៃជំនឿ ។ FIGUIERE

៥១- ក្នុងពេលជក់ចិត្តនឹងគ្រឿងសំណល់អ្វីមួយ ខ្ញុំច្រើនតែនឹកឃើញដល់ភ្នែកអ្នកសុំទាន ដែលខំសម្លឹងខ្ញុំមិនពព្រិច ។

៥២- ពេលវេលាគឺជាចង្កោមទុក្ខយូរអង្វែង បានជាពេលវេលាវាផ្លាស់ប្តូរជានិច្ច ។

**៥៣-** ចិត្តសប្បុរស គឺជាអាវុធស្មារតីខ្លាំងបំផុត ដែលធម្មជាតិបានបង្កើតមក ឱ្យយើងប្រើប្រាស់ ដើម្បីយកឱ្យបានដោយងាយនូវភាពសុក្រិតរបស់មនុស្ស ។

FINOT

**៥៤-** បណ្ដាពាក្យសរសើរដែលត្រូវគេទាត់ចោល បើចេះរបៀបត្រឡប់ជាមានកម្លាំងខ្លាំងទៅវិញ ហើយវាក៏អាចរាបសាល្អបើទុកជាឱ្យទៅតាមកាលៈទេសៈធម្មតា ប៉ុន្តែគប្បីរក្សាទុកតែប្រការណាដែលសមរម្យប៉ុណ្ណោះ ។

FONTENELLE

**៥៥-** ទ្រឹស្ដីជាកំពូលខាងចរិយាសាស្ត្រ អាចជំនួសពាក្យស្លោកដទៃទៀតគឺ*:* *«មិត្តមិនគប្បីធ្វើអ្វីឬនិយាយអ្វីដែលមិត្តមិនចង់ឱ្យគេដឹងឮ»* ។

**៥៦-** ការគួរសម គឺជាការលាតត្រដាងបង្ហាញ ឬការធ្វើតាមនៃគុណធម៌សង្គម បើគួរសមពិតប្រាកដ គឺជាការលាតត្រដាងបង្ហាញបើគួរសមបោកប្រាស់គឺជាការធ្វើតាម ។ ហើយបណ្ដាគុណធម៌សង្គមគឺជាគុណធម៌ដែលធ្វើឱ្យយើងមានប្រយោជន៍ ហើយឱ្យបានស្រួលជាមួយនឹងមនុស្សដែលនៅជុំវិញយើងផង ។

**៥៧-** កិត្តិយសគឺជាសុភមង្គលនៅក្នុងលោកនេះ ដូចគ្នានឹងការជួយសង្គ្រោះ គឺជាសុភមង្គលនៃលោកនាយ : កិត្តិយសគឺជាកលល្បិចនៃអ្នកវាងវៃក្នុងករណីមានអំពើអាក្រក់មកបៀតបៀនខ្លួន ។

DUCLOS

**៥៨**- មនុស្សមិនស្មោះត្រង់ហើយធ្វើជាស្មោះត្រង់ គឺជាមនុស្សក្លែងខ្លួនបន្លំកំហុសរបស់អ្នកដទៃ ក៏ដូចកំហុសរបស់ខ្លួនឯងដែរ។ មនុស្សស្មោះត្រង់គឺជាមនុស្សដែលស្គាល់កំហុសរបស់ខ្លួន ហើយហ៊ានទទួលកំហុសថែមទៀត ។ LA ROCHEFOUCAULD

**៥៩**- ផ្តន្ទាទោសដោយកំហឹង មិនមែនជាការដាក់ទណ្ឌកម្មទេ គឺជាការសងសឹកទៅវិញ ។ LAROUSSE ROCHEFORT

**៦០**- បើមិត្តចង់ឱ្យគេជឿមិត្តថា ជាអ្នកពូកែ អ្នកល្អ មិត្តមិនត្រូវនិយាយអ្វីទាំងអស់ ។ PASCAL

**៦១**- ឱ! ព្រេងវាសនាវាស្អប់រត់ចោលខ្ញុំ ពាក្យនេះមនុស្សណាក៏និយាយគ្រប់គ្នាទាំងអស់គ្រប់ពេលវេលា ។

LA FONTAINE

**៦២**- មនុស្សកាចសាហាវគឺចូលចិត្តបោកប្រាស ប្រញាប់ប្រញាល់ដើម្បីលបលួច ដើម្បីលើកជើងផ្គាប់តម្រូវចិត្តគេ ឆ្លាតវាងវៃលាក់លៀម ចូលចិត្តប្រព្រឹត្តអំពើផ្ទុយនិងកិត្តិយសនិងសតិសម្បជញ្ញៈ ។

FENELON

**៦៣**- ព្រេងសំណាងតាមធម្មតា គឺជាបណ្តាស្ត្រីអ្នកមាន គេចាយវាយផ្តេសផ្តាសធ្វើឱ្យរលាយផ្ទះសម្បែង ដែលកន្លែងនោះហើយបាននាំមកឱ្យគេនូវទ្រព្យសម្បត្តិទៅថ្ងៃមុខ ។ CHAMFORT

**៦៤**- រូបសម្រស់នាំឱ្យល្អមើល បញ្ញានាំឱ្យសប្បាយរីករាយ ការភ្ញាក់ផ្អើលនាំឱ្យមានតណ្ហា មានតែចិត្តល្អទេ ដែលអាចរក្សាហើយចងវាទុក ។

PETRARQUE

**៦៥**- ជើងមិនមែនជាភ្នែកទេ ភ្នែកក៏មិនមែនជាជើងដែរ ប៉ុន្តែទាំងពីរមុខនេះគឺនៅនឹងខ្លួនមនុស្ស អ្វីណានាំឱ្យអន្តរាយដល់ជើងក៏វាមានឥទ្ធិពលមិនល្អដល់ភ្នែកដែរ ។

SAINT PAUL

**៦៦**- មនុស្សកំណាញ់ គ្មានធ្វើប្រយោជន៍អ្វីដល់អ្នកណាទាំងអស់ហើយវាជាសត្រូវលេខមួយរបស់វា ។

LA BRUYERE

**៦៧**- ជាមិត្តជាភក្តិហើយ ទោះបីមនុស្សនោះធ្វើទាស់ចិត្តយើង១០០ដងក៏ដោយ តែជួយឱ្យយើងមានប្រយោជន៍ម្តងក៏គ្រប់គ្រាន់ហើយ ។

Mme SWETCLINE

**៦៨**- ការអានសៀវភៅល្អៗមិនខុសណានឹងការសន្ទនាជាមួយ មនុស្សស្មោះត្រង់ប្រពៃមានបញ្ញា នៃសតវត្សមុនៗដើម្បីស្មោះយោបល់ហើយក៏ជាការសន្ទនាពិចារណាយ៉ាងជ្រៅជ្រះបញ្ជាក់ឱ្យយើងមានសត្យារម្មណ៍ ខ្ពង់ខ្ពស់ ។

DESCARTES

**៦៩**- គ្រាប់ពេជ្រមានតម្លៃយ៉ាងណា តម្លៃមនុស្សក៏ដូច្នោះដែរ ។ ប៉ុន្តែគ្រាប់ពេជ្រវាមានទំហំ វាភ្លឺ វាបានគេឆ្នៃល្អ ហើយវាមានតម្លៃជាក់លាក់ច្បាស់លាស់ ប៉ុន្តែបើខុសពីទំហំនេះវិញ វានឹងក្លាយទៅជាគ្មានតម្លៃគ្មានអ្នកណាទិញឡើយ ។

CHAMFORT

**៧០**- ចង់បំភ្លេចអ្នកណាម្នាក់នោះ គឺយើងនឹកទៅដល់អ្នកនោះហើយ។

**៧១**- មនុស្សយើងទាំងអស់ដូចគ្នានូវពាក្យសម្ដី ប៉ុន្តែខុសគ្នាតែត្រង់អំពើប៉ុណ្ណោះ ។

MOLIERE

**៧២**- មាសដូចគ្នានឹងព្រះអាទិត្យ ធ្វើឱ្យក្រមួនរលាយហើយធ្វើឱ្យផុករឹងស្ងួត ធ្វើឱ្យព្រលឹងមនុស្សខ្ពង់ខ្ពស់ ហើយកាន់តែខ្ពង់ខ្ពស់ទៅទៀត ប៉ុន្តែធ្វើឱ្យព្រលឹងមនុស្សថោកទាប ក៏កាន់តែថោកទាបទៅទៀតដែរ ។

RIVAROL

**៧៣**- មិនអាចទៅជាអ្នកចេះខ្ពស់យល់ជ្រៅបានទេ បើយើងចូលចិត្តអានតែអ្វីដែលយើងចូលចិត្ត ។ Y. YUBERT

**៧៤**- ប្រការអាក្រក់គេមិនបាច់រៀនទេ វាកើតឡើងពេញពាសជាធម្មតាដូចជាបន្លាដែលវាកើតនៅនឹងដីចំការ ដែលគេបោះបង់ចោល ។

LACORDIAIRE

**៧៥**- កាលណាមិត្តជួបនឹងការលំបាកវេទនា មិត្តត្រូវនឹកគិតដល់អ្នកណាដែលលំបាកវេទនាជាងមិត្រ គំនិតនេះគឺជាឱសថមួយយ៉ាងល្អមិនភាន់ច្រឡំ ។

Mme de MAINTENON

**៧៦**- មនុស្សឆ្លាតវាងវៃ ក្នុងអំឡុង៦ខែត្រូវដូររបៀបទាក់ទងរបស់ខ្លួនម្តង ដើម្បីធ្វើឱ្យមនុស្សដែលខ្លួនធ្លាប់ទាក់ទងនោះគេចូលចិត្ត ។

BRULAT

**៧៧**- បាននិយាយចេញនូវការឈឺចាប់ គឺបានលួងលោមខ្លួនឯងហើយ ។

ALEXANDRE DUMAS PERE

**៧៨**- គេមិនសូវនឹកស្តាយដោយគេបាននិយាយតិចនោះទេ គេច្រើននឹកស្តាយដោយគេបាននិយាយច្រើន ។

**៧៩**- បណ្តាគំនិតដូចគ្នានឹងផ្ទាំងសំពត់ព្រំផ្កាដែលគេមូរ ការសន្ទនាបើកមុខឡើង ហើយលាតត្រដាងនៅក្រោមពន្លឺព្រះអាទិត្យ ។

THEMISTOCLE

**៨០**- មនុស្សសប្បាយច្រើនមិនសូវចេះកែប្រែខ្លួនទេ ជានិច្ចកាលគេថាខ្លួនគេល្អប្រសើរណាស់ពីព្រោះលុយកាក់ទ្រព្យសម្បត្តិ វាមកលើកតម្កើងនូវគំនិតអាក្រក់របស់គេ ។

LA ROCHE FOUCAULD

៨១- សេចក្តីគួរសមវាមានតម្លៃដូចគ្នានិងស្រមោល នៅនឹងផ្ទាំងរូប វានាំឱ្យមានកម្លាំងហើយវានាំឱ្យលេចឡើង ។

LA BRUYERE

៨២- ត្រូវធ្វើនូវអំពើយុត្តិធម៌ ដោយមិនចាំបាច់គិតទៅដល់ការអរគុណសងគុណអ្វីឡើយ ។

SENEQUE

៨៣- ចិត្តស្មោះត្រង់ អាចផ្តល់សេចក្តីល្អច្រើនដល់គុណធម៌ ប៉ុន្តែបើគ្មានចិត្តស្មោះត្រង់គ្មានគុណធម៌ណាមានតម្លៃទាំងអស់ ទោះបីមនុស្សនោះមានតម្រិះវិជ្ជាខ្ពង់ខ្ពស់យ៉ាងណាក៏ដោយ។ បើខ្វះចិត្តស្មោះត្រង់គេមិនត្រូវជឿតាមទេ ។

WASHINGTON

៨៤- ពេលវេលាគឺជាមាសពេជ្រ ចំពោះមនុស្ស ដែលមានអាយុពេញវ័យបន្ទាប់មកទៀតពេលវេលានោះ វាទៅជាប្រាក់ហើយដល់ទៅចាស់ ពេលវេលានោះ វាគ្រាន់តែជាស្ពាន់ទៅវិញ ។

FRANKLIN

៨៥- ជីវិតមនុស្ស វាវិលវង់ដូចកង់រទេះមិនចេះឈប់ ដូចល្បែងលេង កើតបានជាមនុស្សបន្តគ្នា អ្នកខ្លះប្រកបទៅដោយកិត្តិយសអ្នកខ្លះប្រកបទៅដោយមាសប្រាក់ អ្នកខ្លះទៀតក៏បានកើតមកនឹងគេដែរ ។

D. DUMAS PERE

៨៦- ការស្គាល់តម្លៃប្រាក់កាក់ ហើយការធ្វើពលិកម្មប្រាក់កាក់ដោយសារភារៈកិច្ច ឬដោយសារករណីមានគ្រោះនោះហើយ គឺជាគុណធម៌ជាក់ស្តែង ។

SENANCOURT

៨៧- នៅក្នុងជីវិត មានឧក្រិដ្ឋកម្មបួនយ៉ាង : ទោសទីមួយគឺការប្រឆាំងនឹងសាសនា - ទីពីរប្រឆាំងនឹងទំនៀមទម្លាប់ ទីបីប្រឆាំងនិងសេចក្តីស្ងប់ស្ងៀម ទីបួនប្រឆាំងនិងសេចក្តីសុខសាន្តប្រជារាស្ត្រ ។

MONTESQUIEU

៨៨- បណ្តាអនុស្សាវរីយ៍នៅក្នុងពេលវេទនាឈឺចាប់ មិនគប្បីរំលឹកឡើងវិញនៅក្នុងពេលសប្បាយរីករាយ ហើយក្នុងពេលវេទនាក៏មិនត្រូវរំលឹកឡើងវិញនូវរឿងសប្បាយរីករាយនោះដែរ ។

SACI

៨៩- ការខ្មាសអៀនចំពោះអំពើល្អ គឺជាឫសគល់នៃអំពើអាក្រក់ទាំងអស់ ការខ្មាសអៀនចំពោះអំពើអាក្រក់គឺជាឫសគល់នៃអំពើល្អទាំងអស់ ។

BOURDALOUE

៩០- ត្រូវតស៊ូចំពោះប្រការទាំងបីខាងក្រោមនេះគឺ ចំពោះជម្ងឺក្នុងខ្លួន ចំពោះសេចក្តីល្ងង់ខ្លៅក្នុងខួរក្បាលនិងបណ្តាតណ្ហាក្នុងចិត្តថ្លើម ។

PYTHAGORE

**៩១-** គេមិនរៀនតែនៅក្នុងសៀវភៅប៉ុណ្ណោះទេ ប៉ុន្តែគេរៀននៅក្នុងការងារផ្ទាល់ខ្លួន និងការពិសោធន៍ជាក់លាក់នៅក្នុងជីវិតមនុស្ស ។
MAUVEZIN

**៩២-** មិនត្រូវនិយាយពីរឿងខ្លួនយើងឱ្យសោះ ទោះបីល្អអាក្រក់ក៏ដោយ អ្នកណាអំនួតគឺជាមនុស្សកោងឈ្លើយ អ្នកណាទម្លាក់ខ្លួនគឺជាមនុស្សល្ងង់ ។ ARISTOTE

**៩៣-** បណ្តាលមិត្រយុវជនអ្នកត្រូវចងចាំនៅក្នុងខួរក្បាល នូវពាក្យចាស់អប់រំត្រឹមត្រូវ ដែលគេអានច្រើនគ្នា នាំឱ្យមានបញ្ញាក្លៀវក្លា ។
R L. D'ARGENSON

## សេចក្តីស្នេហាអនុលោមទៅតាម
##ចារិកមនុស្សនិងសញ្ជាតិ

**៩៤-** សេចក្តីស្នេហាលេចឡើង ដោយរាប់រយបែបអនុលោមទៅតាមលក្ខណៈមនុស្សសញ្ជាតិនិងរូបរាង ។

**៩៥-** ចំពោះមនុស្សមានសាច់ឈាមច្រើន សេចក្តីស្នេហាច្រើនប្រែប្រួល។

**៩៦-** ចំពោះមនុស្សយង់ឃ្នងកោងកាច ស្នេហាទៅជាកាចសាហាវគំរាមកំហែងក្តៅក្រហាយ ។

**៩៧-** ចំពោះមនុស្សកាមរាគ ស្នេហាគឺជាល្បែងលេងមិនខឹងមិនក្តៅហើយមិនស្តាយស្រណោះ ។

**៩៨-** ស្នេហាចំពោះបារាំង គឺឆ្មើងឆ្មៃ គេស្រឡាញ់ស្រីដោយរូបរាងហ៊ុំហាខាងក្រៅ ដោយសេចក្តីឆើតឆាយឬដោយពាក្យសម្តីដែលគេនិយាយសរសើរប្រាប់ខ្លួន ឬក៏ដោយសារពាក្យបញ្ជោររបស់អ្នកដទៃ បារាំងជាមនុស្សផ្តាច់ការក្នុងរឿងប្រចណ្ឌ ហើយមិនធម្មតាទៀតផង ។

**៩៩-** ចំពោះអេស្ប៉ាញ៉ុល គឺគេមានសេចក្តីស្នេហាច្រើនណាស់គេស្រឡាញ់ប្រពន្ធយ៉ាងខ្លាំងក្លាងងឹតងងល់ ទោះបីស្រីនោះគេមិនសូវពេញចិត្តក៏ដោយ ។ ប៉ុន្តែដល់កាលណាគេបានស្រីនោះហើយ គេត្រឡប់ជាបោះចោលយ៉ាងស្រួល ។

**១០០-** ចំពោះ អង់គ្លេស គេយល់ថាប្រពន្ធរបស់គេ គឺជាវត្ថុកម្មសិទ្ធិ របស់គេ គេបានជ្រើសរើសសំអិតសំអាងយកមក ។ ស្រីនោះ គឺជាសម្បត្តិរបស់គេទាំងអស់ អ្វីដែលស្រីនោះមានត្រូវតែល្អ នោះហើយដែលហៅថាសម្មាធិកា ។

**១០១-** ចំពោះអ៊ីតាល្លី គេយល់ថាសេចក្តីស្នេហា គឺជាចំណីរបស់ជីវិត គេរស់នៅដើម្បីស្នេហា ។ គេស្រឡាញ់ហើយគេស្រឡាញ់ នារីទាំងអស់ប្រពន្ធនីមួយៗគេសុទ្ធតែស្មោះត្រង់ទាំងអស់ ។

**១០២-** អាលីម៉ង់ គឺមានការរវើរវាយក្នុងសេចក្ដីស្នេហា ស្រីៗពេញចិត្តប្ដី ដោយសារឧត្តមគតិ ដោយសារស្មារតី ជាជាងដោយសារខ្លួនប្រាណ សម្ភារៈ ។

**១០៣-** ចំពោះរុស្ស៊ី សេចក្ដីស្នេហាបែបសោះអង្គើយ គេមានស្នេហា ម្ដងម្កាលបែបកម្រោល សាហាវហើយឃោរឃៅផង ។

**១០៤-** ចំពោះជនអាស៊ី សេចក្ដីស្នេហាគេចាត់ជាកំពូល ពិភពលោកទៅហើយ តាំងពីចិន យួន ជប៉ុន ។

**១០៥-** មានច្រើនបែបដើម្បីទៅជាវរជនម្នាក់ៗ គេអាចទៅជាវរជនដោយការពារជាតិនឹងកាំភ្លើង លំពែង ឬ ក៏ដោយសាការពង្រីកទឹកដី ការស្រាវ-ជ្រាវរកឃើញវិទ្យាសាស្ត្រ ឬការបង្កើតឧស្សាហកម្ម ភ្ញាក់រលឹកចំពោះជាតិមានមនោសញ្ចេតនាថ្លៃថ្នូរ ចេះស្រឡាញ់អ្នកតូចតាចឃើញគេដូចជាកូនចៅ ត្រូវសន្ដោសគ្នាឡើងជួយឧបត្ថម្ភគ្នា ជាពិសេសឱ្យចេះស្រឡាញ់គ្នា។
EMILE FAGUET

**១០៦-** ពេលវេលាវាដើរយឺតណាស់ ចំពោះមនុស្សខ្ជិល ប៉ុន្តែជីវិតរបស់គេទៅជាខ្លីទៅវិញ ។
PASCAL

**១០៧-** អ្នកណាឧស្សាហ៍សង្ស័យ គឺធ្វើឱ្យអ្នកជិតខាងក្បត់ខ្លួនទៅវិញ។
VOLTAIRE

១០៨- សតិសម្បជញ្ញៈ គឺជាសៀវភៅចរិយាយ៉ាងល្អវិសេស ដែលយើងត្រូវតែអាន នឹងសួរវាជានិច្ច។

PASCAL

១០៩- មនុស្សទំនេរសម្លាប់ពេលវេលា តែពេលវេលាសម្លាប់មនុស្សនៅទំនេរ ។

CAMMENSON

១១០- ត្រូវឱ្យកូនក្មេងស្គាល់ភារៈកិច្ចរបស់វា ដើម្បីទៅថ្ងៃក្រោយវាស្គាល់ករណីយកិច្ចធ្វើជាមនុស្ស ។

KANT

១១១- រស់ គឺដើម្បីដឹង គឺដើម្បីសង្ឃឹម ដើម្បីស្រឡាញ់ ដើម្បីសរសើរអនុវត្តនូវអំពើល្អ ។

E. RENAN

១១២- អយុត្តិធម៌មួយចំពោះមនុស្សម្នាក់ គឺជាការគំរាមកំហែងចំពោះមនុស្សទូទៅ ។

MONTESQUIEU

១១៣- ស្ត្រីភេទប្រើការប៉ិនប្រសប់របស់ខ្លួន ប៉ិនប្រសប់ណាស់យកសំពត់បិតភ្នែកយើង ហើយគេនៅបន្ទោសយើងថា : មកពីយើងល្បេះដើងតាមគេ ។ PAUL BOURGET

**១១៤-** ជីវិតមនុស្សវាខ្លីណាស់ ហេតុនេះកុំស្ទាក់ស្ទើរអី គិតឃើញកិច្ចការអ្វីមួយ ខ្ញុំឱ្យគេអនុវត្តភ្លាម ។

NAPOLEON

**១១៥-** បើយើងគ្រប់សង្កត់តណ្ហាបាន នោះគឺជាគុណធម៌មួយយ៉ាងធំហើយ ។

PASCAL

**១១៦-** បើមិនឆាប់ក៏យូរ មនុស្សណាដែលគិតហើយសរសេរមនុស្សនោះត្រូវតែត្រាបានមតិមហាជន នឹង ពាក្យចចាមអារាម ដូចមិត្តយល់ស្រាប់ អ្នកនោះនឹងត្រូវសាកលលោកផង ។

D′ALEMBERT

**១១៧-** វាជាការងាយក្នុងការជិះជាន់ខ្ញុំ ប៉ុន្តែមិនងាយធ្វើឱ្យខ្ញុំថោកទាបអាក្រក់បានទេ ។

J.J ROUSSEAU

**១១៨-** មេរៀនជូរចត់នៃអពមង្គល គឺផ្តល់ឱ្យដល់គំនិតគិតឆ្ងាយនៃទឹកចិត្តថ្លៃថ្នូរ នឹងខួរក្បាលបញ្ញាវាងវៃ ។

ALEXANDRE DUMAS PERE

**១១៩-** រាប់អានអ្នកធំដូចជាភ្លើងឆេះ មិនគប្បីនៅជិតពេក ឬឆ្ងាយពេកទេ។

DIOGENE

**១២០-** មានគំនិតខ្លះកខ្វក់ ថោកទាបដូចសំរាម ដោយលោភ ផលប្រយោជន៍ ក៏ដូចជាគំនិតខ្លះថ្លៃថ្នូរ ចូលចិត្តកិត្តិយស នឹងចរិយា។ បណ្តាគំនិតថោកទាបនោះគឺ មានតែសប្បាយ នឹង បានលុយហើយមិនឱ្យរបេះមួយកាក់។ ប្រការអាក្រក់ថោកទាបនេះមិនមែនជាបងប្អូនសាច់ញាតិមិត្តមិនមែនពលរដ្ឋ ឬ អ្នកកាន់សាសនាណាទេ វាក៏មិនមែនមនុស្សដែរ វាគឺជាប្រាក់ ។

LA BRUYERE

**១២១-** មតិមហាជន គឺ ជាក្សត្រយានីនៃពិភពលោក។

PASCAL

**១២២-** អ្នកណាមិនចេះស្តាប់គឺ មិនចេះនិយាយ ។

GIRARDIN

## សិល្បៈដើម្បីរស់ឱ្យបានល្អ

**១២៣-** ក្នុងមួយអាទិត្យត្រូវមានគំនិតល្អមួយ ។

**១២៤-** ក្នុងកិច្ចការវាត្រូវការមិនឈប់នូវគំនិតថ្មី ។

**១២៥-** ត្រូវមានចរិតលោភលន់យោបល់ ។

**១២៦**- ត្រូវស្មោះត្រង់ បើមិត្តបោកប្រាស់ របុិញរបុញ បក្សពួក មិត្តមិនអាចស្គាល់បាននូវការពិតទេ ។

**១២៧**- ត្រូវហាត់ចិត្តឱ្យមានការប្តេជ្ញាចិត្ត ។

**១២៨**- ត្រូវអនុវត្តរាល់ថ្ងៃ នូវគំនិតមួយ ។

**១២៩**- ត្រូវកត់សម្គាល់ក្នុងកូនសៀវភៅ នូវគំនិតទាំងអស់របស់មិត្តដែលវាមកម្តងបន្តិចៗឱ្យមិត្ត ។

**១៣០**- កម្លាំងនៃមនោគតិបូករួមនឹងគំនិតល្អ នោះហើយគឺជារូបមន្តនៃជ័យជម្នះ ។

**១៣១**- មានមនោគតិល្អិតល្អោចខ្លះ អាចទៅជាសំខាន់បាន បើគំនិតថែរក្សាវាទុក ។

**១៣២**- បើមិត្តជាពាណិជ្ជករ មិត្តត្រូវពង្រីកមនោគតិ ដើម្បីឱ្យមានភ្ញៀវច្រើន ។

**១៣៣**- ជាធម្មតា ត្រូវពិចារណាឱ្យហ្មត់ចត់អំពីការឃោសនានៅក្នុងទស្សនាវដ្តី នឹង សារពត៌មាន ។

**១៣៤-** គំនិតឃោសនាលក់របស់យ៉ាងល្អមួយ គឺគំនិតដែលវាបង្កើតនូវការប្រៀបធៀបរវាងផលិតផល ដែលត្រូវសរសើរ នឹង សេចក្តីត្រូវការរបស់មនុស្ស ។

**១៣៥-** ភាគច្រើនវីរបុរស គឺជាផ្ទាំងរូប បើចង់គោរពវីរបុរសទាំងនោះ គេមិនទៅឈរមើលជិតពេកទេ។

**១៣៦-** នៅក្នុងជីវិតមានប្រការដែលសំខាន់ជាងការសប្បាយរីករាយ នឹងសម្ភារៈ សំខាន់ជាងលុយកាក់ សំខាន់ជាងសុខភាព... របស់នោះគឺ ការយកចិត្តទុកដាក់ នឹងវិទ្យាសាស្ត្រ ។

**១៣៧-** គេមិនត្រូវប្រើពាក្យសម្តីឱ្យខ្ពស់ហួសពេក ជាជាងការធ្វើជាក់ស្តែងទេ ។

## ភាសិត

**១៣៨-** វត្ថុទាំងអស់ដែលភ្លឺ មិនមែនសុទ្ធតែមាសទេ ។

**១៣៩-** លុយកាក់អាចធ្វើអ្វីបានទាំងអស់ ។

**១៤០-** សូវឱ្យតិចជាជាងឱ្យខ្ចីច្រើនហើយមិនសង ។

**១៤១-** របស់បានដោយអយុត្តិធម៌ វាមិនចម្រើនទេ ។

**១៤២**- មនុស្សម្នាក់ៗ វាមានការជំនាញផ្សេងៗ ។

**១៤៣**- នៅក្នុងការងារទើបគេដឹងថាជាងពូកែ ។

**១៤៤**- បើសាបស្រូវ គេច្រូតស្រូវ ។

**១៤៥**- សៀវភៅអាក្រក់ដុះច្រើនណាស់ ។

**១៤៦**- គ្មានកូលាបណា ដែលគ្មានបន្លានោះទេ ។

**១៤៨**- ជួយខ្លួនឯងសិន ទើបទេវតាជួយក្រោយ ។

**១៤៩**- ធ្វើម្ហូបចក ត្រូវមានកន្ទុយ ។

**១៥០**- ជួនកាលអភមង្គល ក៏ល្អដែរ ។

**១៥១**- ឆ្នាំត្រូវទឹកក្តៅ ខ្លាចទឹកត្រជាក់ ។

**១៥២**- សើចនឹងគេ គេនឹងសើចវិញ ។

**១៥៣**- ការនៅទំនេរជាម្តាយ នៃ កំហុសទាំងអស់ ។

**១៥៤**- ស្រឡាញ់កូនត្រូវវាយជេរ ស្អប់កូនត្រូវផ្អែមល្ហែម ។

**១៥៥**- គ្រូយ៉ាងម៉េច សិស្សអ៊ីចឹង ។

**១៥៦**- ចង្ក្រានឆ្នាំងយើងវាគ្រាន់ជាង ។

**១៥៧**- ផ្ទះអ្នកណាអ្នកនោះដឹង ។

**១៥៨**- រើផ្ទះ ៣ ដង ដូចភ្លើងឆេះផ្ទះ ។

**១៥៩**- តែឃ្លាន គឺឆ្ងាញ់ ។

**១៦០**- ត្រចៀកស្តាប់មិនឮទេ កាលណាឃ្លានបាយ ។

**១៦១**- ស៊ីបានដឹងថាឆ្ងាញ់ ។

**១៦២**- មានតិចជាជាងគ្មាន ។

**១៦៣**- អ្នកណាស្រឡាញ់ខ្ញុំ ស្រឡាញ់ទាំងឆ្កែខ្ញុំផង ។

**១៦៤**- មនុស្សស្លាប់គ្មានតម្លៃប៉ុនឆ្កែនៅរស់ទេ ។

**១៦៥**- ពស់ស្លាប់អស់ពិស ។

**១៦៦**- ពេលយប់ ផ្ទះស្លឹក ដូចគ្នាផ្ទះថ្ម ។

**១៦៧**- កុំដាក់នង្គ័លពីមុខគោ ។

**១៦៨**- គេមិនអាចបង្ខំលាឱ្យផឹកទឹក កាលណាវាមិនស្រេកនោះទេ ។

**១៦៩**- ក្ដាមនៅស្រែណាវាកាត់ស្រែនោះ ។

**១៧០**- កំពឹសនៅក្នុងផ្ទះ គ្រាន់ជាងបង្កងនៅក្នុងបឹង ។

**១៧១**- មនុស្សត្រូវគ្នា គឺដូចគ្នា។

**១៧២**- ជិតមនុស្សចេះវាចេះ ជិតមនុស្សល្ងង់វាល្ងង់ ។

**១៧៣**- ពត់ឫស្សីទាន់វានៅខ្ចី ។

**១៧៤**- មនុស្សម្នាក់ៗចិត្តដោយខ្លួន ។

**១៧៥**- ក្រមិនមែនជាកំហុសរបស់មនុស្សទេ ។

**១៧៦**- សុខចិត្តក្រ គឺសង្ឃឹមមាន ។

**១៧៧**- សាមគ្គីជាកម្លាំង ។

**១៧៨**- ពាក្យអាក្រក់ឮឆ្ងាយ ។

១៨៩- កូនពូកែជាងឪ គឺគ្រួសារមានភ័ព ។

១៩០- មិនទាន់បានជួបគ្នាផង ទៅជាព្រួយចិត្តបែកបាក់ ។

១៩១- មនុស្សក្រ កូនច្រើន ។

១៩២- មានចេះតែមានថែម ក្រចេះតែថែមកូន ។

១៩៣- ធ្វើគុណបានទោស ។

១៩៤- ធ្វើគុណឱ្យមនុស្សរមិលគុណ គឺបានទោស ។

១៩៥- គឺជាមនុស្សខ្ជិលដែលធ្វើការតែថ្ងៃបុណ្យ ។

១៩៦- គេស្គាល់មិត្តល្អនៅក្នុងគ្រាក្រ ។

១៩៧- សូម្បីតែទេវតា ក៏ត្រូវការលុយដែរ ។

១៩៨- កាលឈើយកដំរីទៅបន់ ដល់គ្រាន់យកពងមាន់ទៅថ្វាយ ។

១៩៩- កំភ្លាញស្លាប់ពីព្រោះមាត់ ។

២០០- តាំងចិត្តឱ្យនឹង អ្វីក៏បានដែរ ។

**២០១**- តូងតាងដេកផ្លូវ ។

**២០២**- ចង់បានផ្លែស៊ីត្រូវដាំដើម ។

**២០៣**- ពេលស្លាប់ អ្នកណាក៏ដូចតែគ្នាដែរ ។

**២០៤**- ខំបំភ្លេចអ្នកណាមួយ គឺនឹកអ្នកនោះ ។

**២០៥**- ពងពស់ញាស់មកពស់ ពងមាន់ញាស់មកមាន់ ។

**២០៦**- ស្នេហាគឺទុក្ខព្រួយ ។

**២០៧**- កុំស្មានថាចិត្តគេ ដូចចិត្តយើង ។

**២០៨**- ដេញឈើប៊ីដាក់ត្រចៀកគោ ។

**២០៩**- របស់អាក្រក់លក់ថោក ។

**២១០**- ពេលវេលា គឺប្រាក់ ។

**២១១**- ដេកពីព្រលប់ ងើបពីព្រលឹម ។

**២១២**- បានថ្មីចោលចាស់ ។

២១៣- គ្មានកន្លែងណាគ្រាន់ជាងកន្លែងយើងទេ ។

២១៤- ឱបច្រើនពេក វាមិនជុំទេ ។

២១៥- និយាយច្រើន គេមិនខ្លាច ។

២១៦- ចិត្តល្អគ្រាន់ជាងខោអាវល្អ ។

២១៧- មឹះៗកេះឆ្នាំងបាយឆ្លុះ ។

២១៨- ជិតភ្លើងវាក្ដៅ ជិតផ្សែងវាប្រឡាក់ ។

២១៩- មនុស្សអន់ច្រើនអួត មនុស្សខ្សោយច្រើនធ្វើខ្លាំង ។

២២០- ឱ្យដល់អ្នកក្រ គឺឱ្យព្រះខ្ចី ។

២២១- ស្រែកឡូឡាពេញភូមិ ។

២២២- ក្រលំហៀ ។

២២៣- ចង់ស៊ីស្រក់ទឹកមាត់ ។

២២៤- អស់ខឹង ។

**២២៥**- នាងតីស្នាកៀង ស៊ីរះទាំងសង្វាង ។

**២២៦**- ធ្វើបុណ្យធ្វើទានឱ្យអ្នកមាន ។

**២២៧**- មនុស្សគួរឱ្យខ្លាចគឺ មនុស្សមឹះៗ ។

**២២៨**- មនុស្សមានកាន់តែមានថែម ។

**២២៩**- ចុះទឹកក្រពើ ឡើងលើខ្លា ។

**២៣០**- គយដេក កុំកេះគយឱ្យអង្គុរ ។

**២៣១**- ខូចពីឪពុកម្តាយ វាសាយដល់កូន ។

**២៣២**- លំបាកវេទនាហើយរស់ ល្អជាងមានអំណាចហើយស្លាប់ ។

**២៣៣**- និយាយស្តីស្មោះត្រង់ ។

**២៣៤**- ភ្នែកឆ្ងាយណាយចិត្ត ។

**២៤៥**- មនុស្សមាត់អាក្រក់ ច្រើនតែចិត្តល្អ ។

**២៤៦**- មានពេលខ្លះ យើងនិយាយផ្សេងពីចិត្តយើង ។

**២៤៧**- មនុស្សម្នាក់ៗគិតតែខ្លួនឯង អាទិទេពគិតឱ្យមនុស្សទាំងអស់គ្នា ។

**២៤៨**- សំណូមរពររាស្ត្រគឺសំណូមពរព្រះ ។

**២៤៩**- គ្មានលុយ គ្មានអ្នកបម្រើ ។

**២៥០**- មិត្តដោយសាលុយមានច្រើន ដូចសត្វត្រចៀកកាំទំនៅដំបូលផ្ទះ។

**២៥១**- គិតលុយត្រឹមត្រូវ មានមិត្តភក្តិល្អ ។

**២៥២**- ទិញឥវ៉ាន់មិនព្រមពិនិត្យមើល (ត្រូវគេបោក) ។

**២៥៣**- មិត្តភាពដូចឆ្កែនឹងឆ្មា ។

**២៥៤**- ឆ្មាមិននៅកណ្តុរឡើងរាជ ។

**២៥៥**- ចេះឯងតោងរអែងចេះគេ ។

**២៥៦**- គ្មានភ្លើងណា ដែលគ្មានផ្សែងនោះទេ ។

**២៥៧**- ភ្លើងលាងស្អាតទាំងអស់ ការក្រខ្វិចក្រខ្វក់ ។

**២៥៨**- ត្រូវសន្សំសំចៃ ។

**២៥៩**- ប្លន់អំណាចរបស់គេ ។

**២៦០**- ស៊ីមុនសងក្រោយ ។

**២៦១**- របរណាដែលមានមនុស្សធ្វើច្រើនវាមិនចំណេញទេ ។

**២៦២**- ថ្ងៃដែលកន្លងផុតទៅហើយវាមិនដូចគ្នាទេ ។

**២៦៣**- រឿងវាវែងនាំឱ្យថ្ងៃវាខ្លី ។

**២៦៤**- ភ្នំពេញគេមិនមែនធ្វើតែមួយថ្ងៃបានទេ «*ត្រូវព្យាយាមយូរអង្វែង*»។

**២៦៥**- យកពងមាន់ទៅផ្ញើនឹងក្អែក ។

**២៦៦**- កំពុងតែនិយាយពីអ្នកណា អ្នកនោះស្រាប់តែមកដល់ ។

**២៦៧**- រស់ក្នុងនាទីដែលមានគ្រោះថ្នាក់ ។

**២៦៨**- មានពេលខ្លះ យើងធ្វើនូវអំពើដែលយើងមិនចង់ធ្វើ ។

**២៦៩**- ចចកវាមិនស៊ីគ្នាវាទេ ។

**២៧០**- ពេលវេលាផ្សេង ទម្លាប់ក៏ផ្សេង ។

**២៧១**- ពេលវេលាគឺជាចៅហ្វាយធំ ។

**២៧២**- អ្នកណាមានពេលវេលាគឺមានរស់ ។

**២៧៣**- មនុស្សពូកែមិនបាច់ប្រដាប់ប្រដាល្អទេ ។

**២៧៤**- តម្លៃដីស្រែវាអាស្រ័យនឹងមនុស្សភ្ជួរ ។

**២៧៥**- ខ្ញុំមិនទទួលដឹងឮក្នុងរឿងនេះទេ ។

**២៧៦**- លេងដៃគឺជាការលេងរបស់អ្នកថោកទាប ។

**២៧៧**- ដេកលក់យ៉ាងស្រួល ។

**២៧៨**- គេនិយាយច្រើនពីបងក្នុងពេលដែលបងមិននៅ ។

**២៧៩**- ត្រូវគេមួលស្លឹកត្រចៀក ។

**២៨០**- ឈរទន្ទឹងចាំចង់បាក់ជើង ។

**២៨១**- ផ្ទាញ់ផ្ទាលមនុស្សម្នាក់ «*ផ្ចាញ់ផ្ចាល់*» ។

**២៨២**- រឿងមួយបានការពីរ ។

# ភាសិតផ្សេងៗ

**២៨៣-** គុណសម្បត្តិដែលមិត្តត្រូវមានខានមិនបានគឺ : នឹងន ប្រយ័ត្ន-ប្រយែង ទន់ភ្លន់និងរៀងវៃ ។

**២៨៤-** មិត្តត្រូវខំធ្វើខ្លួនឱ្យសប្បាយរីករាយ ពិសេសនៅពេលដែលមិត្តលែងនិយាយទាក់ទងជាមួយភ្ញៀវ ។

**២៨៥-** សុភមង្គលរបស់មិត្ត មួយភាគធំអាស្រ័យមិត្តធ្វើឱ្យមាន ទើបមិត្តយល់ថាខ្លួនមិត្តជាទុក្ខវេទនា នោះគឺមិត្តយល់ថាឆាកជីវិតសម្រាប់តែទុក្ខវេទនា។ ផ្ទុយទៅវិញអ្នកមានសុទិដ្ឋិនិយម ច្រើនសើចសប្បាយ ច្រើនរីករាយ អ្នកនោះយល់ថាឆាកជីវិត គឺសម្រាប់តែសប្បាយរីករាយ ។

**២៨៦-** ពេលមានទុក្ខព្រួយខ្លាំង ព្រោះមានអ្នកមានគុណស្លាប់ ឬព្រោះបែកបាក់ពីអ្នកដែលជាទីស្រឡាញ់ ឬព្រោះពីការអ្វីផ្សេងទៀតនោះ មិត្តគួរឧទ្ទិសព្រលឹងជូនព្រះអាទិទេព ដើម្បីសម្រន់បានខ្លះនូវទុក្ខព្រួយនោះ ។

**២៨៧-** ក្នុងចំណោមទុក្ខព្រួយទាំងអស់ មានតែទុក្ខព្រួយចំពោះការស្លាប់របស់អ្នកដ៏មានគុណ ឬអ្នកជាទីស្រឡាញ់នោះទេ ដែលខ្លោចផ្សាបំផុត ។

**២៨៨-** ការកំសាកបំផុតរបស់មនុស្ស គឺការឈប់ធ្វើសកម្មភាពនៅពេលជួបប្រទះឧបសគ្គ ។ មិនប្រឹងតស៊ូទៅទៀតដោយយល់ថាខ្លួនអស់ផ្លូវហើយ។

**២៨៩-** បេះដូងរបស់មិត្ត មិត្តមានសិទ្ធិប្រគល់ជូនចំពោះមនុស្សម្នាក់ដោយឡែក ក្នុងរយៈកាលជូនចំពោះសង្គមនោះ ។

**២៩០-** ទោះបីមានគេស្រឡាញ់រាប់អានមិត្តច្រើន ទោះបីមានគេជឿទុកចិត្តមិត្តច្រើន ទោះបីគាប់ជួនពេលឱកាសល្អហុចឱ្យក៏ដោយសូមមិត្តកុំអះអាងថាការងារមិត្តសុទ្ធតែបានសម្រេចផលដូចបំណង។ មិត្តគួររង់ចាំពេលវេលាល្អ ពិនិត្យឱ្យល្អិត ស្ទាបអង្អែលមនុស្សឱ្យស្គាប់ច្បាស់ នោះទើបការងារមិត្តសោះនឹងកើតវិប្បដិសារីថ្ងៃក្រោយ ។

**២៩១-** គេខ្លាចបំផុតតែមនុស្សខ្លាច ខ្លាចគេដឹងការខ្លួន ខ្លាចគេធ្វើបាបខ្លួន ខ្លាចគេរកចាប់ខ្លួន ខ្លាចរហូតអត់ធ្វើបានការអ្វីទាំងអស់ ។ ឃើញគេរាប់អានខ្លួនយ៉ាងរាក់ទាក់ ឃើញគេចូលចិត្តខ្លួននោះមិត្តកុំឆាប់ទុកចិត្តគេពេកព្រោះធម្មតាមនុស្សរបៀបនេះសេពគប់នឹងមិត្តពុំបានយូរទេ ។

**២៩២-** បាត់មុខអ្នកជាទីស្រឡាញ់ រហូតមិនអាចត្រឡប់មកវិញនោះមិត្តឈឺចិត្តខ្លោចផ្សាឥតមានអ្វីប្រៀប នឹងឃើញខ្លួនមិត្តឯកោអនាថា មិត្តនឹងថប់ដង្ហើមស្លាប់ថ្ងៃណាមួយពុំខាន ។

**២៩៣-** រស់នៅក្នុងលោក កុំចង្អៀតចង្អល់ចិត្តពេកពីព្រោះអ្នកចង្អៀតចង្អល់ចិត្ត ពុំសូវមានមនោសញ្ចេតនាចំពោះអ្នកនៅជុំវិញខ្លួនឯងទេ ហើយក៏ពុំសូវមានអ្នកណាស្ម័គ្រសមាគមជាមួយខ្លួនដែរ ។

**២៩៤-** របស់នៅក្នុងលោក កុំធុញទ្រាន់និងការលំបាក កុំអស់សង្ឃឹមនិង

ឆាកជីវិត កុំរួញរាចំពោះមុខឧបសគ្គ គ្រប់ពេលវេលា ត្រូវតាំងចិត្តក្លាហាន អង់អាចស្វិតស្វាញជានិច្ច ទើបឃើញជីវិតមានតម្លៃកាត់ថ្លៃមិនបាន ។

**២៩៥**- ក្នុងឆាកជីវិត មានការខ្លះមិត្តត្រូវខាំមាត់អត់ធន់រហូត ទោះបីការនោះជាមេក្រមីស៊ីរូងដល់ខួរក្នុងឆ្អឹងមិត្តក៏ដោយ។ ពីព្រោះការនោះបើមិត្តបញ្ចេញ គឺមិត្តជាអត្តឃាតករប៉ុណ្ណោះ ។

**២៩៦**- ក្នុងឆាកជីវិត សូមមិត្តស្មោះត្រង់ កុំមានគំនិតបោកប្រវ័ញ្ចន៍មិត្ត ក៏គង់មានអ្នកចិត្តល្អជួយមិត្តមិនខាន ។

**២៩៧**- បើមានគេសួរខ្ញុំថា តើអ្នកស្រឡាញ់អ្នកណាជាងគេក្នុងលោក នោះខ្ញុំឆ្លើយថាខ្ញុំស្រឡាញ់មេខ្ញុំជាងគេ ។

**២៩៨**- ខួរក្បាលមានតែមួយកំបង់ដៃប៉ុណ្ណោះ ប៉ុន្តែហ៊ានគិតហ៊ានធ្វើនូវអំពើមហាសង្វៀម ដោយមិនបាច់ខ្ចីពឹងដល់ព្រះអាទិទេពឡើយ។

**២៩៩**- មិត្តធ្វើអំពើល្អជាប្រយោជន៍ដល់សង្គម សូមចិត្តចេះតែធ្វើតទៅទៀតចុះដោយសេចក្ដីស្ងៀមស្ងាត់មិនបាច់ថ្លែងទេ រួចថ្ងៃក្រោយសង្គមគង់តែដឹងទេអំពើរបស់មិត្តនោះ ។

**៣០០**- រស់នៅក្នុងលោក មិត្តសំអាងលើសេចក្ដីសុចរិតរបស់ចិត្តសំអាងលើអំពើល្អបរិសុទ្ធរបស់មិត្ត សំអាងលើស្មារតីយុត្តិធម៌របស់មិត្ត នោះមិត្តគ្មានខ្លាចសត្រូវណាទាំងអស់ ។

**៣០១-** ក្នុងការរស់នៅក្នុងសង្គម តាមកាលៈទេសៈខ្លះមិត្តកុំចងគំនុំគុំគួន កុំព្យាបាទសងសឹក ពីព្រោះអំពើអាក្រក់របស់គេ ចំពោះមកលើមិត្តជួនកាលទោះជាកត្តាសំខាន់ផ្តល់ផលប្រយោជន៍ឱ្យមិត្តវិញទេ។

**៣០២-** មិត្តត្រូវធ្វើខ្លួនឱ្យទៅជាមនុស្សសន្សំសំចៃ ប៉ុន្តែកុំពីព្រោះតែសន្សំសំចៃ ហើយទុកឱ្យខូចការងារធំ ខូចការងារមានប្រយោជន៍ដល់ខ្លួននឹងសង្គមនោះ ។

**៣០៣-** ការណាដែលមិត្តមិនដឹង សូមកុំធ្វើដឹងកុំថាគេខុស សូមមិត្តទុកពេលពិនិត្យហ្មត់ចត់សិន ជួនកាលមិត្តពិនិត្យហ្មត់ចត់ហើយនៅតែមិនដឹងទៀត ពីព្រោះសមត្ថភាពមិត្តដឹងមិនដល់ ។

**៣០៤-** ទោះបីជួបការលំបាកនិងគ្រោះថ្នាក់យ៉ាងណាក៏ដោយ សូមមិត្តរក្សាអាកប្បកិរិយានឹងធឹងនិងហ្មត់ចត់ឱ្យបាន ។

**៣០៥-** មិត្តបានរៀបចំពាក្យសម្តីជាច្រើន សម្រាប់និយាយជាមួយអ្នកដែលមិត្តត្រូវជួប ប៉ុន្តែដល់ពេលជួបឱកាសមិនហុចឱ្យមិត្តនិយាយបានអស់ នោះសូមមិត្តកុំបង្ខំនិយាយដើម្បីបង្អស់ពាក្យមិត្តឡើយ ។ បើមិត្តធ្វើដូច្នេះបាន នោះមិត្តនឹងទៅជាអ្នកមានសមត្ថភាពអាចធ្វើការធំបាន ។

**៣០៦-** សូមមិត្តរក្សាទុកឱ្យបាន នូវស្មារតីក្លាហាន នឹងន រៀងរៃ អាកប្បកិរិយារីករាយស្រស់ស្រាយ និងប្តូរផ្តាច់ ។

**៣០៧-** សូមមិត្តនិយមប្រើអណ្ដាតនិងស្លាបប៉ាកការរបស់មិត្ត ឱ្យមានប្រយោជន៍ដល់សង្គមនិងខ្លួនឯងជានិច្ច ។

**៣០៨-** មានការពីរដែលមិត្តត្រូវជៀសវាងឱ្យបាន គឺការដណ្ដើមនិយាយកាត់ពាក្យសម្ដីគេ និងការនិយាយពីរឿងអាក្រក់គេ ។

**៣០៩-** មនុស្សដែលចូលចិត្តដណ្ដើមនិយាយតែឯង ឬនិយាយច្រើនហួសពីគេចង់ដឹង មនុស្សធុននោះសម្បូរដូចស្មៅ ។

**៣១០-** ពេលសរសេរក៏ដូចពេលនិយាយដែរ មិត្តត្រូវរិះគិតឱ្យហ្មត់ចត់ថ្លឹងភាគថ្លឹងផល កាលៈទេសៈអនុញ្ញាតឱ្យសរសេរឱ្យនិយាយឬទេ?

**៣១១-** បើមិត្តចង់ធ្វើជាយុទ្ធជនម្នាក់ប្រកបដោយសច្ចៈ សូមមិត្តសម្អាតឱ្យអស់កំហុស កំលាក់លៀមនៅកំហុសឱ្យសោះហើយតាំងស្មារតីថាធ្វើការដើម្បីមនុស្សជាតិ ។

**៣១២-** មួយវិនាទីនាឡិកាមានប្រយោជន៍ច្រើនណាស់ នៅក្រោមមេឃនេះមានការងារច្រើនណាស់ដែលត្រូវសម្រេចក្នុងមួយវិនាទី។

**៣១៣-** ការចាប់ដៃមួយប្រកបដោយទឹកមុខរីករាយ មិនបង់ខាតអីទេប៉ុន្តែអាចផ្ដល់ឱ្យមិត្តនូវផលប្រយោជន៍យ៉ាងច្រើន ។

**៣១៤-** ដាច់ខាតកុំទិចទៀនអ្នកណាឡើយ តែខំធ្វើការដែលខ្លួនយល់ថា

មានប្រយោជន៍ដល់ខ្លួននិងសង្គមនោះទៅ ។

**៣១៥-** មនុស្សលោកកើតមកដំបូងឋិតនៅក្នុងសំពៀតធម្មជាតិ ដោយសារការអប់រំ ការលត់ដំ មួយថ្ងៃបន្តិចៗយូរៗទៅបានឡើងដល់កំណត់មនុស្សមានអារ្យធម៌។ អារ្យធម៌នៅត្រង់ការរស់នៅរបស់មនុស្សមានរចនាវិចិត្រថ្មីៗ និងប្លែកជាងសត្វតិរច្ឆាន ។

**៣១៦-** មិត្តចង់ឱ្យមានសុភមង្គលគ្រប់ម្ភៃបួនម៉ោង មិត្តត្រូវតែមានឧត្តមគតិខ្ពង់ខ្ពស់និងត្រចះត្រចង់មានកម្មវិធីធ្វើសមកម្មភាព ដើម្បីភោជ្ជភស្តុនិងកម្លាំងសតិអារម្មណ៍ ។

**៣១៧-** បើគ្មានសេចក្តីស្នេហាមួយយ៉ាងបរិសុទ្ធ បើមិនដឹងរបៀបបញ្ជោរស្នេហានោះឱ្យសំដៅទៅរកផលប្រយោជន៍ទេ នោះឆាកជីវិតជួបប្រទះនិងគ្រោះថ្នាក់មិនឈប់ឈរឡើយ ។

**៣១៨-** ទោះបីជួបប្រទះនិងការគួរឱ្យទោមនស្ស អាក់អន់ចិត្តយ៉ាងណាក៏ដោយក៏គួរអត់ធន់បន្តការងារនោះទៅទៀត ដរាបបានសម្រេច ។

**៣១៩-** ការងារប្រយោជន៍សង្គម មិត្តធ្វើម្នាក់ឯងមិនរួច ម៉្តេចមិត្តមិនចាត់តាំងតាមច្បាប់សង្គមវិទ្យា ដើម្បីរកអ្នកស្ម័គ្រសមាគមជួយធ្វើការ។ ការងារបរាជ័យនោះ មួយភាគធំមកពីមិត្តឆ្លាតកែឆ្នៃវិធីធ្វើការឱ្យល្អ ។

**៣២០-** វិធីប្រស្រ័យទាក់ទងនិងអ្នកដទៃ ជាគោលការត្រូវឱ្យរឹងប៉ុន្តែ

ជាអកប្បកិរិយាជាឬកពា ទាំងពាក្យឱ្យសម្តីត្រូវឱ្យទន់ភ្លន់ ។

**៣២១-** ពីព្រោះកាលៈទេសៈ ពីព្រោះឧបសគ្គដែលកើតពីគ្នាឯងក្បត់គ្នាឯង នោះ មិត្តបន្ធូរបន្ថយខាងសកម្មភាព បន្ថយអាហារឱ្យខួរក្បាល បន្ថយការបង្កើនឧត្តមគតិ ប៉ុន្តែមិនអាចឈ្នះសត្រូវទាំងនោះបាន បើមិត្តមិនបំភ្លេចការចងកំហឹងចំពោះសត្រូវទាំងនោះ ។

**៣២២-** តាមសភាវរបស់មិត្ត មិនខុសអំពីលក្ខណៈសត្វសេះទេពេលណាក៏វាចង់តែលោតចេញពីក្រោល ដើម្បីរកញីរកឈ្មោលដែរ។ មិត្តគួរតែឱ្យវាមានខ្សែបង្ហៀជាប់ជានិច្ច ដើម្បីបង្អន់ចំណង់រំជួលរបស់វា ហើយផ្តល់ឱ្យវានូវប្រភពអង់អាចក្លាហានវិញ។

**៣២៣-** មិត្តចង់ឱ្យមានមិត្តភក្តិច្រើន ចង់បានមិត្តល្អជួយសម្រួលការងារមិត្តច្រើន នោះមិត្តរក្សាបុគ្គលិកលក្ខណៈជាមនុស្សទៀងត្រង់និងមិនចង្អៀតចង្អល់ ។

**៣២៤-** ដើម្បីជ្រើសរើសមនុស្សធ្វើកល្យាណមិត្ត ប្តូររស់ប្តូរស្លាប់ជាមួយមិត្តនោះ សូមមិត្តកុំប្រកែប្រកាន់ការឆ្គាំឆ្គងបន្តិចបន្តួចរបស់គេកុំប្រទូសរ៉ាយតបគេវិញ អត់ឱនខន្តីឱ្យគេ ជួយដោះស្រាយទុក្ខធុរៈគេតាមលទ្ធភាពដែលមិត្តអាចធ្វើបាន ។

**៣២៥-** ពេលនិយាយការអីជាមួយអ្នកណា ទោះវែងឬខ្លី មិត្តនិយាយឱ្យច្បាស់លាស់ ម៉ត់ចត់និងយ៉ាងប្រយ័ត្នប្រយែង ។

**៣២៦-** ការសម្រេចផលអ្វីម្យ៉ាងៗមិនមែននៅត្រង់ចំណេះវិជ្ជា មិនមែននៅត្រង់បានរៀនច្រើននោះទេ ដែលសំខាន់បំផុតនៅត្រង់ឆ្លាតទាក់ទង ឈ្លាសវៃក្នុងការងារ និងអត់ធន់ក្នុងការងារ ។

**៣២៧-** មិត្តច្រើនស្មានថាគេល្អដូចខ្លួនមិត្ត។ នៅក្នុងពិភពលោកមិត្តធ្វើល្អមានមួយភាគចូលចិត្តស្រឡាញ់ តែក៏មានមួយភាពស្អប់ឈ្នានីសដែរ ។

**៣២៨-** មនុស្សភាគច្រើន ពេលជួបឧបសគ្គឆាប់អស់សង្ឃឹម អ្នកនោះពិបាកធ្វើបានការងារធំដុំណាស់ គេខំប្រឹងឆ្នៃការលំបាកនោះឱ្យទៅជាងាយឱ្យទៅជាសម្រេចផលបាន លុះត្រាតែមានកម្លាំងគ្រប់គ្រាន់ និងស្មារតីប្តូរផ្តាច់ ។

**៣២៩-** ក្នុងសង្គមមិនតិចទេ អ្នករៀនពូកែខាងវិស័យវិទ្យាសាស្រ្តប៉ុន្តែអ្នកយកវិទ្យាសាស្រ្តនោះមកអនុវត្តបង្កបង្កើតផល ដើម្បីសង្គមវិញមិនច្រើនទេ។

**៣៣០-** កើតទាន់សង្គមមានអារ្យធម៌ បានសង្គមអប់រំខ្លួនឱ្យមានអារ្យធម៌ ទាក់ទងស្ម័គ្រសមាគមជាមួយមនុស្សមិនទាន់ជ្រួតជ្រាបអារ្យធម៌ ប្រសើរជាងទាក់ទងជាមួយមនុស្សឃោរឃៅ ។

**៣៣១-** បើមិត្តមិនអាចធ្វើជាព្រះអាទិត្យបំភ្លឺមនុស្សសង្គម ពិភពលោកបានទេ ម៉េចមិត្តមិនធ្វើភ្លើងទៀនបំភ្លឺមនុស្សពីរបីនាក់ដែលនៅជុំវិញខ្លួនមិត្ត? ។

**៣៣២-** ទម្លាប់ឱ្យខ្លួនមានស្មារតីច្បាស់លាស់ : ពេលពន្យល់គេអំពីគំនិតរបស់មិត្ត សូមមិត្តពន្យល់ឱ្យច្បាស់ ថាតើមិត្តចង់និយាយអំពីរឿងអី កុំឱ្យវែង តែកុំឱ្យខ្លីដល់ស្តាប់មិនបាន ។

**៣៣៣-** ក្រៅអំពីភារៈជាអ្នកអប់រំ មិត្តស្តាប់គេឱ្យច្រើនជាងនិយាយឱ្យគេស្តាប់ ។ បើនិយាយ គួរនិយាយតែរឿងណាមិនសន្សំសត្រូវនោះបានហើយ ។

**៣៣៤-** ពីមុនធ្លាប់ធ្វើការអីនឹងអ្នកណា ដល់ពេលបែកគ្នាឈប់ទាក់ទងគ្នាសូមមិត្តកុំនិយាយពីរឿងគេឱ្យសោះ ។ បើគេមានគុណលើយើង នោះយើងរំលឹកគុណគេបាន ។

**៣៣៥-** ការងារដំបូង មិត្តគួរខំប្រឹងប្រែងឱ្យអស់សមត្ថភាព ទើបអាចជំរុញការងារនោះទៅមុខបាន ។ ក្រោយមកសោះនឹងពិបាកដូចមុនទៀតហើយ ។ លទ្ធផលប្រាកដជាផ្តល់ឱ្យមិត្តពុំខាន ។

**៣៣៦-** មនុស្សម្នាក់ៗ តែងមានល្អមានអាក្រក់។ មិត្តគួរឆក់យកការល្អរបស់គេមកឆ្នៃឱ្យទៅជាមានប្រយោជន៍ដល់ខ្លួនគេផង ដល់សង្គមផង ។ មិត្តកុំអង្គុយមើលតែបំណាំអាក្រក់របស់គេនោះ។

**៣៣៧-** បើគេតាមព្យាបាទមិត្ត បង្ករឿងអាស្រូវផ្សេងៗដាក់មិត្តៗនៅតែធ្វើល្អដរាប មិនយូរប៉ុន្មានសត្រូវនោះនិងក្លាយមកជាមិត្តវិញ ។

**៣៣៨-** គេធ្វើបាបមិត្តនៅពេលមិត្តខ្វះសមត្ថភាព លុះដល់ថ្ងៃក្រោយមិត្តមានវាសនាទៅជាអ្នកមានអំណាច សូមមិត្តកុំសងសឹករឿងនោះ។ ពេលនោះអ្នកផងកោតក្រែងថាមិត្តចំជាល្អមែន ។

**៣៣៩-** មិត្តត្រូវដាច់ខាត កុំឱ្យមានសោះនូវរឿងនិយាយដើមគេ ឬនិយាយបញ្ឆិតបញ្ឆៀងឱ្យគេនៅពេលកំបាំងមុខពីគេ។

**៣៤០-** ហាត់រៀនវិធីទាក់ទងតាមផ្លែ តែហាត់រៀនវិធីនិយាយតិចតាមគេវិញ ។

**៣៤១-** ក្នុងការរស់នៅ ត្រូវបើកឱ្យទូលាយខាងការទាក់ទង។ គេមិនមែនជាមិត្តជិតស្និទ្ធ ប៉ុន្តែគេជាសមាជិកសង្គមដែរ យ៉ាងអញ្ចឹងមិត្តគួរគោរពរាប់អានគេឱ្យទូលំទូលាយ បានច្រើនកាលណាល្អកាលណោះ ។

**៣៤២-** ដើម្បីឱ្យងាយស្រួលក្នុងការទាក់ទង ត្រូវប្រើអាកប្បកិរិយាទន់ភ្លន់ចូលចិត្តស្តាប់គេច្រើនជាងនិយាយឱ្យគេស្តាប់ ។ ហើយនិយាយសរសើរគេប្រសើរជាងនិយាយបង្អាប់ឬចំអន់គេ ។

**៣៤៣-** បើបានធ្វើធំ កាន់ការច្រើននិងសំខាន់ៗចង់ឱ្យអ្នកនៅក្រោមបង្គាប់ស្តាប់បង្គាប់ផង ចង់ឱ្យការងារប្រព្រឹត្តទៅបាន ហើយស្រួលផង មិត្តត្រូវជឿទុកចិត្តលើសមត្ថភាពការងាររបស់អ្នកដែលមិត្តប្រគល់ការឱ្យនោះ ។

**៣៤៤-** បើមិត្តមិនទាន់ស្គាល់គេច្បាស់ បើមិត្តមិនយល់ពីការងារគេមិត្តកុំ

ប្រញាប់គេ ប៉ុន្តែមិត្តមិនត្រូវឆាប់ជឿគេពេកទេ ។

**៣៤៥-** ក្នុងពេលពិភាក្សាទាក់ទង មិត្តត្រូវប្រើទឹកមុខរីករាយស្រស់ស្រាយជានិច្ច ។

**៣៤៦-** ទទួលធ្វើការអ្វីមួយហើយ ឬទទួលភារៈបំពេញបេសកម្មអ្វីមួយហើយ ត្រូវអន់ធន់ធ្វើការនោះឱ្យសម្រេចនិងហ្មត់ចត់ ។

**៣៤៧-** ធ្វើសកម្មភាព ប៉ុន្តែបើខ្លាចគេទិតៀន នោះពុំអាចធ្វើអ្វីបានសោះឡើយ ។

**៣៤៨-** បើចង់ឱ្យមានអ្នកធ្វើសហការ ជាមួយមិត្តឱ្យអស់ចិត្តពីពោះសូមមិត្តកុំអាលបញ្ចេញគោលបំណងមិត្តប្រាប់គេ តែត្រូវប្រើផ្លូវមនោសញ្ចេតនាឱ្យច្រើន ធ្វើឱ្យជិតស្និទ្ធ រួចរើសពេលវេលាល្អអូសទាញគេសន្សឹមៗទៅតាមមនោវិថីរបស់មិត្តចុះ ។

**៣៤៩-** រាល់ពេលដែលមិត្តត្អូញត្អែរជាមួយអ្នកដទៃ ឬជាមួយមិត្តភក្តិអំពីសេចក្តីទុក្ខវេទនារបស់ខ្លួន ឬរបស់អ្នកដទៃ នោះជាការបង្អស់កម្លាំងមិត្តចោលអត់ប្រយោជន៍ទេ ។ មិត្តគួរចៀសវាងការនិយាយអត់ប្រយោជន៍។

**៣៥០-** មិត្តមិនមែនគ្រាន់តែត្រូវចៀសវាងអំពើអាក្រក់របស់មិត្តដែលសង្គមបានដឹងនោះទេ មិត្តថែមទាំងត្រូវចៀសវាងអំពើអាក្រក់របស់មិត្តដែលមិត្តម្នាក់ឯងដឹងនោះផង ។

**៣៥១-** កុំពីព្រោះការស៊ី ការស្លៀកពាក់ មិត្តធ្វើឱ្យខូចបុគ្គលិកលក្ខណៈជាមនុស្ស ដើម្បីទៅធ្វើអំពើអប្រិយភាពវិញនោះ ។

**៣៥២-** ប្រយ័ត្ន ក្រែងពេលដែលមិត្តកំពុងទិតៀនគេអំពីរឿងអ្វីមួយនោះ អ្នកស្ដាប់គេតបមិត្តវិញអំពីអំពើប្រព្រឹត្តដែលមិត្តកំពុងធ្វើផ្ទុយពីពាក្យ សម្ដីមិត្ត។

**៣៥៣-** អ្នកខ្លះប្រកាន់ចិត្តថា ការងាររបស់បក្សពួកខ្លួនសុទ្ធតែត្រូវទាំងអស់ ហើយការងាររបស់បក្សពួកដទៃសុទ្ធតែខុសទាំងអស់។ អ្នកណាគិតដូច្នេះ អ្នកនោះខុសហើយ ខុសត្រង់យល់ថាការងាររបស់ខ្លួនរបស់បក្សពួកខ្លួនល្អមួយរយភាគរយ ហើយឈប់កែឆ្នៃឱ្យល្អថែមទៀតនោះ ។

**៣៥៤-** ធ្វើមនុស្សមិនមែនគ្រាន់តែរៀនឱ្យពូកែ ហើយធ្វើខ្លួនឱ្យស្អាតដោយធ្វើជាបរិស័ទនៃសាសនា រួចគិតថាគ្រប់គ្រាន់ហើយនោះទេ ពីព្រោះខ្លួននៅក្នុងសង្គម ខ្លួនជាតំណក់ទឹកមួយក្នុងចំណោមទឹកមួយសមុទ្រ បើទឹកសមុទ្រប្រៃទឹកមួយតំណក់របស់មិត្តត្រូវតែប្រៃដែរ ។ ហើយបើទឹកសមុទ្រសាប តំណក់ទឹកមួយរបស់មិត្តត្រូវតែសាបដែរនេះច្បាប់ធម្មជាតិពុំអាចកែឆ្នៃបានឡើយ ។

**៣៥៥-** នៅក្នុងលោកមិត្តខំធ្វើល្អឱ្យគេ ខំសម្ដែងការស្និទ្ធស្នាលរាក់ទាក់ចំពោះគេ តែមានអ្នកខ្លះនៅតែច្រណែនឈ្នានីសមិត្តមិនឈប់ឈរ តើមកអំពីអ្វី ? ......។

**៣៥៦**- ការសំខាន់របស់មនុស្សក្នុងមួយជីវិត នៅត្រង់ស្លាប់រស់។ គឺស្លាប់រស់ព្រោះឧត្តមគតិអ្វីមួយនោះឯង ។

**៣៥៧**- និយាយចំពោះតែវិស័យបច្ចេកទេសវិញ សមត្ថភាពធ្វើឱ្យគុណភាពមួយថ្ងៃកាន់តែប្រសើរឡើង ។

**៣៥៨**- ការរស់នៅ បើមិនចំណុះអាទិទេពទេ មានតែការឆ្នៃពេលវេលាគ្រប់នាទីឱ្យមានប្រយោជន៍ដល់ខ្លួន និង ដល់សង្គម ហើយបើបោះបង់ពេលវេលាចោលទៀត នោះរស់នៅឱ្យតែធ្ងន់ផែដី ។

**៣៥៩**- បើមានស្នេហាចំពោះអ្នកណាហើយ តែងតែព្រួយបារម្ភក្រែងអ្នកនោះមានគ្រោះថ្នាក់បាត់សុភមង្គល បើមិនដូច្នោះទេគឺស្នេហាបោកប្រាស ស្នេហាសត្វកង្កង់ ។

**៣៦០**- ពេលចាប់ផ្តើមធ្វើកិច្ចការ គឺជាមួយអ្នកណាម្នាក់ ឬច្រើននាក់កុំអាលជឿទុកចិត្តថាគេអស់ពីចិត្តអស់ពីពោះឧបត្ថម្ភការងារយើង។ កុំអាល់ជឿថាគេជឿយើងស៊ុបឱ្យសោះ ។ តែដល់ពេលណាគេទិតៀនចំពោះការបរាជ័យរបស់យើង ក៏យើងកុំអាលថាគេស្អប់យើងដែរ ។

**៣៦១**- ក្នុងឋានៈជាអ្នកទទួលបន្ទុកការងារមួយ មិត្តជួបប្រទះនិងការទិតៀនអំពីសំណាក់សមាជិកមួយរូប ឬច្រើនរូប សូមមិត្តទុកគេជាថ្នាំពេទ្យតាំងស្មារតីនឹងនថ្លឹងមើល តើគេថានោះគួរឬមិនគួរ ។ ថ្នាំណាត្រូវជម្ងឺយើង

យើងកុំខ្លាចនឹងផឹកវា ថ្នាំណាមិនត្រូវជម្ងឺយើង យើងបោះចោលដោយអរគុណម្ចាស់គេផង ។

**៣៦២-** សូម្បីតែពាក្យទិតៀន ដោយបំណងបំផ្លាញការងារយើងក៏ដោយ ក៏គួរយើងយល់ថាមានប្រតិកម្ម ហើយបើមានប្រតិកម្មក៏គង់មានប្រតិលាភ ។ ព្រោះប្រតិកម្មវាជាកម្លាំងជម្រុញឱ្យការងារយើងឈានទៅមុខឈោងចាប់ប្រតិលាភ ។

**៣៦៣-** បើបាតដៃគ្មានដំបៅគេមិនខ្លាចលូកដៃទទួលយកថ្នាំពិសទេ។ មានតែបាតដៃដែលមានដំបៅទេ ដែលមិនហ៊ានលាដៃលូកទៅទទួលយកថ្នាំពិស ពីព្រោះថ្នាំពិសចូលមុខដំបៅវាក្តៅផ្សាឈឺចាប់ណាស់។

**៣៦៤-** គោលគំនិតជាមធ្យោបាយអាថ៌កំបាំង សម្រាប់បង្កើតសេចក្តីស្និទ្ធស្នាលនិងឥទ្ធិពលទៅលើអ្នកដទៃសម្តីទន់ភ្លន់ជាមធ្យោបាយចំហ តែបើមិនប្រើការប្រព្រឹត្តខ្លះថែមលើសម្តីទន់ភ្លន់នោះពុំបានផលទេ ។

## ពាក្យសម្តីមាស

**៣៦៥-** បើស្រឡាញ់គ្នាមែន ខុស៩ដងចោលឱ្យគ្រប់១០ដងទៅ។
**«បទវិចារណ»**

**៣៦៦-** មិនចេះប្រចណ្ឌឬមួយក៏ប៉ះត្រង់ណា ប្រចណ្ឌត្រង់នោះ នោះហើយគឺជាការថោកទាប មិនរវល់ដល់ ឬមួយក៏គិតតែរវល់ដល់ច្រើនពេក ប្រការ

ទាំងពីរនេះសុទ្ធតែគ្រោះថ្នាក់ ។
LI TENA

**៣៦៧**- មានទូកស្នេហាច្រើនណាស់ ដែលលឿនទៅមុខពោរពេលដោយសេចក្តីសង្ឃឹម តែទីបញ្ចប់ត្រូវរលាយបាត់បង់ទៅវិញ... ដោយសារតែប្រការមួយ គឺប្តីប្រពន្ធចូលចិត្តតែរិះគន់គ្នាពេក។
DOROTHY DIX

**៣៦៨**- ជីវិតមួយរស់ក្នុងអាពាហ៍ពិពាហ៍ ត្រូវឱ្យមានកម្រិតថ្នាក់ថ្នមរូបភាពខាងក្រៅ តែត្រូវអនុគ្រោះខាងជម្រៅ ។
ABEL BONNARD

**៣៦៩**- មនុស្សមានឫកត្រឹមត្រូវគួរសម មិនអាចរួមរស់នៅបានស្រួលជាមួយនឹងមនុស្សជាតិគំរោះគំរើយទេ ។
ABEL BONNARD

**៣៧០**- ការជ្រើសរើសដើម្បីរៀបការ បើខុសតែបន្តិចគឺខុសរាប់យោជន៍។
CH. VAGNER

**៣៧១**- ទោះល្អល្អះយ៉ាងណាក៏ដោយ តែធុញទ្រាន់ទៅវាទៅជាខ្ជិលរវល់។ ដូចគ្នានឹងស្នេហាស្និទ្ធស្នាល តែចាស់កាលណា ក្លិនធុំកាន់តែខ្លាំង ។
LA MARTINE

**៣៧២-** ក្នុងបណ្តាកិច្ចការដែលគេយល់ថា គោកគ្រទាំងគ្មានទាក់ទងអ្វីនឹងស្នេហាទាំងអស់ ប៉ុន្តែប្រការនោះក៏មានរឿងរ៉ាវស្នេហាអាចកំបាំងកប់នៅក្នុងនោះដែរ ។

PASCAL

**៣៧៣-** ល្អគឺជាអ្វី? ចំពោះនារីភាគខ្លះគេយល់ថា គឺអ្វីដែលអ្នកនៅជុំវិញគេយល់ថាល្អ ។

LOUIS DE ROBERT

**៣៧៤-** ចង់បានសុភមង្គលនៅក្នុងគ្រួសារ គេត្រូវចេះទ្រាំនឹងទទួល ដើម្បីឱ្យគូសង្សាររបស់យើងរស់នៅបានតាមធម្មតាទៅតាមចរិតរបស់គ្នា ហើយក៏កុំសូវចង់កែប្រែឱ្យហួសហេតុពេក ។

FOSTER WOOD

**៣៧៥-** ការពិតដែលលេចឡើងយ៉ាងច្បាស់លាស់ជាងគេគឺគ្មានអ្វីក្រៅពីមនុស្សនៅក្នុងផ្ទះទេ ស្និទ្ធស្នាលដូចប្តីប្រពន្ធទើបហ៊ាននិយាយនូវពាក្យទ្រគោះ ពាក្យពីរោះ ពាក្យជូជាតិ ។

DOROTHY DIX

**៣៧៦-** ធ្វើការអ្វីៗ ទោះបីជាការអីក៏ដោយ បើយើងមានទេពកោសល្យល្អពូកែជាងគេ នោះហើយគឺជាវិធីដែលធ្វើឱ្យស្រីចូលចិត្ត ហើយគេយកចិត្តទុកដាក់ដល់យើង ។

BALZAC

**៣៧៧-** សេចក្ដីស្នេហារវាងម្ដាយនឹងកូន គឺជាសេចក្ដីស្នេហាមានជម្រៅវាស់មិនបាន អត្តទត្ថភាពបំផុត ហើយក៏ទូលំទូលាយបំផុត ល្អិតល្អោចបំផុត ហើយក៏ខ្ពង់ខ្ពស់បំផុត ល្វង់ល្វិតបំផុត ហើយក៏ភ្លឺស្វាងបំផុត... នេះហើយ គឺជាសេចក្ដីស្នេហានៃអ្នកអភ័ព្វ... វាថ្លៃថ្នូរវិសេសនៅត្រង់នេះឯង។

J. CHARDONNES

**៣៧៨-** បើគេពិនិត្យមើលតែរបៀបស្លៀកពាក់របស់ស្ត្រី គេអាចយល់បាននូវព្រលឹងរបស់ស្ត្រីនោះ ស្លៀកពាក់បែបហ៊ឺហា គឺជាមនុស្សដែលមានចរិតមិនប្រក្រតី ។

ADOLPHE RICARD

**៣៧៩-** ប្ដីប្រពន្ធ ត្រូវខំប្រឹងតស៊ូនឹងប្រការចង្រៃអស់ទាំងនេះទម្លាប់ដែលធ្វើឱ្យធុញទ្រាន់ ។

BALZAC

**៣៨០-** ការផ្ដាប់យកទឹកចិត្តនឹងការទម្លាប់ វាអាចធ្វើឱ្យចរិតនៃមនុស្សដែលយើងស្រឡាញ់ បំបាត់ចោលនូវចរិតអាក្រក់គំរោះគំរើយជូជាតិ ប៉ុន្តែវាក៏អាចធ្វើឱ្យអ្នកដែលយើងស្រឡាញ់គេរសាយចិត្តស្រឡាញ់ខ្លះដែរ ។

LATENA

**៣៨១-** ទម្លាប់វាអាចធ្វើឱ្យអ្វីដែលល្អបំផុត នៅក្នុងលោកនៅជាធម្មតាបាន ។ បណ្ដាអ្នកដែលធ្លាប់រស់នៅក្នុងកន្លែងស្កុកស្គម្ភបំផុតដល់យូរទៅក៏លែងដឹងថាជាកន្លែងស្កុកស្គម្ភល្អហើយ។ ខ្ញុំបានដឹងរឿងមួយ : មានប្ដីម្នាក់មាន

ប្រពន្ធយ៉ាងស្អាត ដល់រស់នៅជាមួយគ្នាបាន៣ឆ្នាំ លោកប្ដីនោះក៏មិនចាំថា ប្រពន្ធខ្លួនមានភ្នែកពណ៌អ្វីផង ។ ការផ្លាស់ប្ដូរមនោសញ្ចេតនានាំឱ្យគ្រោះថ្នាក់ដល់សុភមង្គលគ្រួសារ ប៉ុន្តែទម្លាប់វាគ្រោះថ្នាក់ជាងនេះទៅទៀត ។

Mme DE BIEUX

**៣៨២**- ទម្លាប់នាំឱ្យថោកទាបដល់តម្លៃរស់នៅរបស់មនុស្ស។

PROPERCE

**៣៨៣**- មនុស្សមួយស្លាប់ ព្រលឹងឡើងទៅលើឋានសួគ៌ ដល់ឡើងទៅដល់មាត់ទ្វារ ជួបនឹងអ្នកយាមទ្វារឋានសួគ៌សួរ :

-អ្នកឯងធ្លាប់ឆ្លងកាត់ភ្នក់ភ្លើងសាងបាបហើយនៅ?

-បាទនៅទេ! ប៉ុន្តែខ្ញុំជាអ្នកមានប្រពន្ធ!

-បានហើយ ឡើងទៅចុះ!

**(ពិចារណា)**

**៣៨៤**- មានតែរបស់ល្អពីរទេនៅក្នុងលោក គឺមនុស្សស្រីនិងដួងផ្កាកុលាប

MALHERBE

**៣៨៥**- គ្មានអ្វីឈឺចាប់ដល់មនុស្សស្រីឱ្យស្មើនឹងខ្លួនគេ យល់ថាខ្លួនគេត្រូវអន់ថយចំពោះប្រការអ្វីក៏ដោយ ចំពោះអ្នកដែលនៅជុំវិញគេ ។

GINA LOUBROSO

**៣៨៦**- ចំពោះចិត្តយើង យើងមិនបាច់ឃោសនាដាក់វាធ្វើអ្វីទេយើងមានតែធ្វើតាមវាឬសំពងវាប៉ុណ្ណោះ ។
PROCH PEDRE

**៣៨៧**- បេះដូងរបស់ស្រីវាមិនដែលចាស់ទេ ក្នុងពេលដែលវាមិនស្រឡាញ់ទៀត គឺមកអំពីវាឈប់ដើរ (ឈប់ជីពចរ) ។
PROCH PEDRE

**៣៨៨**- មនុស្សដែលមានស្នេហាពិតប្រាកដ គឺជាមនុស្សដែលគិតទៅដល់តែសុភមង្គលរបស់មនុស្សដែលគេស្រឡាញ់។
BELOISE

**៣៨៩**- ចិត្តសប្បុរស គឺជាគ្រឿងអលង្ការយ៉ាងពិសេសបំផុត របស់ស្ត្រីល្អ។ គ្មានអ្វីធ្វើឱ្យអាក្រក់បានដល់បបូរមាត់ញញឹមយ៉ាងស្មោះទេ មានតែសំណើចចំអកទើបគេស្អប់ ។
SAINT MAURICE

**៣៩០**- លទ្ធផលទូទៅនៃសេចក្ដីស្នេហា គឺធ្វើឱ្យមានសមភាពទាំងអស់ ចំអេសអំអាស ផ្គេសផ្គាស មានក្រ ថ្លៃថ្នូរ ក្មេង ចាស់ មិត្តសត្រូវក៏ត្រូវរលាយបាត់អស់ដែរ ។ ABBE PREVOST

**៣៩១**- ស្ត្រីមានប្ដីមិនខុសណានឹងអ្នកបម្រើទេ ដែលគេយកមកដាក់លើបល្ល័ង្ក ។ BALGAE

**៣៩២-** ស្ត្រីមិនខុសអ្វីនឹងព្រាយកំណាចទេ គេចាប់យើងឱ្យចុះនរកដោយដើរកាត់តាមក្លោងទ្វារឋានសួគ៌ ។

**SAIT CYPRIEN**

**៣៩៣-** អ្វីដែលរួចហើយគឺវាឆ្លងផុត អ្វីដែលរួចហើយគឺវាធុញទ្រាន់ អ្វីដែលរួចហើយគឺវារលាយរលត់។ នេះហើយគឺជាវិធានទូទៅនៃកិច្ចការសម្ភារៈទាំងអស់ មិនចំពោះតែសេចក្ដីស្នេហាទេ ។

**៣៩៤-** បើគ្មានស្រីទេ មនុស្សប្រុសនឹងជាទេព្ដាទាំងអស់ ។

**CICERON**

**៣៩៥-** ទណ្ឌកម្មនៃមនុស្សប្រុស ដែលស្រឡាញ់តែស្រីហួសហេតុពេក គឺធ្វើឱ្យប្រុសនោះវេទនាដោយសារស្រឡាញ់ស្រី ។

**J.JOUBERT**

**៣៩៦-** នៅក្នុងរឿងប្រចណ្ឌ ការស្រឡាញ់ខ្លួនវាដើរតួសំខាន់ជាងសេចក្ដីស្នេហា ។

**ROCHE FOUCAULD**

**៣៩៧-** បណ្ដាប្រការអ្វីទាំងអស់ដែលស្រីៗរៀននៅក្នុងសៀវភៅវាគ្រាន់តែជាស្លាកស្នាមនៃការស្រពិចស្រពិល នៅក្នុងក្បាលប៉ុណ្ណោះ។ កាលណាតែស្រីៗឈឺចាប់ ចិត្តគេជ្រួលឡើង កាលណាការរស់នៅបង្ខិតបង្ខំគេឱ្យ

ពិចារណា ឱ្យត្រិះរិះប្រតិបត្តិការ ទើបគេមានទ្រឹស្តីមួយជាក់លាក់សម្រាប់ជីវិត ។

GINA LOMBROSO

៣៩៨- មនុស្សនៅក្មេង ចូលចិត្តនិយាយអំពីរឿងស្រីៗឬស្នេហាប៉ុន្តែបើតាមខ្ញុំវិញ ចំពោះមនុស្សចំណាស់ក៏ដោយ ក៏មានប្រការដើម្បីនិយាយតិចឬច្រើនឬ គិតដល់រឿងនោះដែរ ។ P. J. STAHL

៣៩៩- ស្រីទើបចេះរបៀបសងសឹកយ៉ាងគ្រោះថ្នាក់ ។

Mme de RIEUX

៤០០- មនុស្សណានិយាយសរសើរពីស្រីៗ គឺជាមនុស្សដែលមិនទាន់ស្គាល់ស្រីច្បាស់លាស់ មនុស្សណានិយាយអាក្រក់ពីស្រីគឺជាមនុស្សដែលមិនស្គាល់អ្វីទាំងអស់ពីរឿងស្រីៗ ។

GAULT LEBRUN

៤០១- ជនដែលជេរបញ្ចោ ឬ និយាយអាក្រក់ពីស្រីច្រើនជាងគេគឺជននោះហើយ ដែលស្រឡាញ់ស្រីស្មោះត្រង់ជាងអ្នកណាទាំងអស់ ។

THEOPHILE GAUTIER

៤០២- ស្នេហាចំពោះមនុស្សប្រុស គឺជារឿងប្រវត្តិស្នេហាមួយចំពោះជីវិតរបស់គេ តែចំពោះមនុស្សស្រីវិញ ស្នេហាគឺជារឿងប្រវត្តិអស់មួយជីវិតរបស់គេ ។

**៤០៣-** ពីអាទិទេពមកដល់មនុស្ស ពីមេឃមកដី មានតែសេចក្តីស្នេហាទេដែលអាចរួបរួមបានហើយហៀហូរពេញពាស។ ស្នេហាវាជាឫសគល់នៃគ្រប់កិច្ចការទាំងអស់ មានស្នេហាទើបបានដឹង មានស្នេហាទើបបានរស់ មានស្នេហាទើបមានសុភមង្គល ស្នេហាមួយតំណក់អាចធ្វើឱ្យសកលលោករលាយបាន ដូចគ្នានឹងខ្យល់ព្យុះធ្វើឱ្យគួស្រូវបោកបក់បាន។

LA CORDAIRE

**៤០៤-** ទណ្ឌកម្មធំបំផុតដែលគេច្រើនតែបួងសួងឱ្យធ្លាក់ចំទៅលើសត្រូវរបស់គេនោះ គឺទណ្ឌកម្ម ឱ្យសត្រូវនោះស្រឡាញ់គេ តែកុំឱ្យគេស្រឡាញ់តបមកវិញ ។

LABOUISSE

**៤០៥-** អាពាហ៍ពិពាហ៍ គឺជាប្រការមួយកំប្លុកកំប្លែងបំផុតនៅក្នុងបណ្តាប្រការនឹងធឹងត្រឹមត្រូវក្នុងជីវិត ។

BEAUHARNAIS

**៤០៦-** ត្រូវក្លាហានទទួលស្គាល់ការពិតនេះ ដែលយើងហៅថា (**ស្រេកឃ្លានសេចក្តីស្នេហា**) ការពិតមានពេលខ្លះគឺយើងស្រេកឃ្លានចង់ឱ្យគេមករណោបរណើបបបោសអង្អែលយើងទៅវិញទេ។

J. DES VIGNE ROUGES

**៤០៧-** មនុស្សណាបាននឹកគិតទៅដល់និម្មិតរូបវិធីនៃទេព្តាស្នេហាដោយទស្សនៈមនុស្សក្មេង គឺជាមនុស្សពូកែ ព្រោះគេយល់បាននូវជីវភាពនៃ

មនុស្សស្នេហា គឺជាជីវិតនៃមនុស្សក្មេង គេហ៊ានធ្វើពលីកម្មដោយងងឹតងងល់ ហ៊ានយករឿងធំដុំមកបំផ្លាញដោយសារកិច្ចការគ្មានបានផល។

MONTAIGNE

៤០៨- មនុស្សស្រីគឺជាមនុស្សមានចរិតហួសហេតុ បើប្រៀបធៀបទៅនឹងមនុស្សប្រុស ស្រីជាមនុស្សបើល្អក៏ល្អហួសហេតុ បើអាក្រក់វិញក៏អាក្រក់ហួសហេតុដែរ ។

LA BRUYERE

៤០៩- មនុស្សស្រីណាដែលគោរពចរិយារបស់ខ្លួន ជាងចំណេះបញ្ញារបស់ខ្លួន គឺជាស្រីលេខមួយនៅក្នុងចំណោមស្រីៗ ។ ស្រីណាគោរពរូបសម្បត្តិរបស់ខ្លួនជាងតម្រិះវិជ្ជារបស់ខ្លួន គឺជាស្រីធម្មតា។ ប៉ុន្តែបើស្រីណាគោរពបុណ្យសក្តិឬវណ្ណៈរបស់ខ្លួនជាងរូបសម្បត្តិរបស់ខ្លួន នោះជាមនុស្សស្រីនៅក្រៅវង្ស ពីព្រោះគេមិនមែនជាមនុស្សឡើយ។

CHAM FORT

៤១០- ស្រីណាក៏ដោយដូចតែគ្នា ជានិច្ចកាលនៅតែធ្វើដូចកូនក្មេងអស់មួយជីវិត ។

ALTRED de VIGNY

៤១១- ប្រការដែលគួរឱ្យស្តាយក្នុងរឿងស្នេហាគឺថា កាលអាយុនៅក្មេងវាគ្មានពិសោធន៍គ្រប់ ដល់ទៅចាស់ត្រឡប់ជាមានពិសោធន៍ច្រើនពេក។

ROCH PEDRE

**៤១២-** ខំប្រឹងបំភ្លេចគេ មានន័យថានៅនឹកដល់គេ មានតែកុំនឹកទៅដល់ ទើបសេចក្ដីស្នេហាវាហើរពណ៌សម្បុរ បាត់អស់ម្ដងបន្តិចៗ ។

**LA BRUYERE**

**៤១៣-** បើគេអាចបន្លាយសុភមង្គលឱ្យ បានយូរបន្ទាប់ពីអាពាហ៍ពិពាហ៍ នោះគេអាចឡើងទៅឋានសួគ៌ក្នុងលោកីយ៍បាន ។

**J.J ROU SSEAU**

**៤១៤-** បើស្រីណាស្រឡាញ់ខ្ញុំដោយអាណិត ខ្ញុំសុំថាកុំស្រឡាញ់ខ្ញុំធ្វើអ្វី ពីព្រោះខ្ញុំមិនមែនជាអ្នកសុំទានទេ ។

MONTAIGNE

**៤១៥-** មនុស្សស្រីណាលេងប្រឡែងនឹងស្នេហា ទោះយូរឬឆាប់ក្ដីក៏ត្រូវតែ ជំពាក់ ពីព្រោះលេងកាំបិតមានថ្ងៃមុតដៃមិនខាន ។

**SAINT PROSPER**

**៤១៦-** គ្មានអ្វីចងភ្ជាប់បាននូវបេះដូងពីរឱ្យស្មើនឹងអង្គុយយំជាមួយគ្នាទេ។

**J.J ROUSSEAU**

**៤១៧-** មនុស្សស្រីណា តែហ៊ានយំនៅចំពោះមនុស្សប្រុស មនុស្សស្រីនោះ លែងធ្វើម្ចាស់ខ្លួនបានទៀតហើយ ។

**BALZAC**

**៤១៨**- យកប្រាក់មកល្បងមើល ទើបដឹងបានថាស្នេហាស្មោះត្រង់ឬមិនស្មោះ ។

ROCHEBRUNE

**៤១៩**- ការដឹងគុណគឺជាផ្លូវកាត់ទៅរកសេចក្ដីស្នេហា ។

THEOPHILE GAUTIER

**៤២០**- មានតែពេលវេលាមិនមែនទ្រឹស្ដីទេ ដែលអាចព្យាបាលបាននូវមុខរបួសស្នេហា ។

PUBLIUS SYRUS

**៤២១**- ពេលវេលា ទោះយឺតឬឆាប់ក្ដីក៏ឈ្នះស្នេហាដែរ ។

LE TASSE

**៤២២**- មនុស្សស្រីដែលចូលចិត្តតែហ៊ឺហាអួតអាងពេក គឺជាស្រីខ្វះការគោរពខ្លួនឯង ។

Mme de RIEUX

**៤២៣**- មនុស្សស្រីមិនចូលចិត្តហ៊ឺហាអួតអាង គឺជាស្រីដែលមនុស្សប្រុសចូលចិត្ត ។ ALPHONSE KAR

**៤២៤**- ជីវិតរបស់មនុស្សប្រុស គឺកេរ្តិ៍ឈ្មោះ ជីវិតមនុស្សស្រីគឺស្នេហា ។

BAL ZAC

**៤២៥**- ចេះស្រឡាញ់ បានសេចក្ដីថា មុនដំបូងបង្អស់ហើយជានិច្ចជាកាល មិនត្រូវឆ្ពឹះឆ្ពៀលជីកឫសជីកគល់មនុស្សដែលយើងស្រឡាញ់នោះទេ។

P. BOURGET

**៤២៦**- រវាងប្ដីប្រពន្ធ ប្រការដែលចង្រៃបំផុត គឺការដែលប្រៀបធៀបប្រពន្ធខ្លួននឹងប្រពន្ធគេ ឬប្រៀបធៀបប្ដីខ្លួននឹងប្ដីគេ ។

EMILE STOCH

**៤២៧**- មានពេលខ្លះ ប្រចណ្ឌគឺមានសមភាព ត្រឹមត្រូវហើយសមរម្យពីព្រោះវាសំដៅទៅលើកិច្ចការពារទ្រព្យសម្បត្តិរបស់យើង។

LA ROCHE FOUCAULD

**៤២៨**- ប្រចណ្ឌវាកើតមកអំពីស្នេហា ហើយវាក៏ស្លាប់ទៅវិញជាមួយស្នេហាដែរ ។

LA ROCHE FOUCAULD

**៤២៩**- គេអាចអនុគ្រោះទៅបានតាមតែចិត្តដែលគេស្រឡាញ់។

LA ROCHE FOUCAULD

**៤៣០**- ការសន្ទនារាប់អានស្មោះត្រង់ មានតែរវាងមនុស្សសប្បុរសទេ ពីព្រោះមូលដ្ឋានរបស់វាគឺមេត្តាធម៌ ហើយដោយសារតែមេត្តាធម៌នេះដែរដែលវាអាចទៅជាថ្លៃថ្នូរបាន ។

ARISTOTE

**៤៣១-** បេះដូងត្រូវទៅមុនស្មារតី ហើយសេចក្ដីសប្បុរសត្រូវទៅមុនការពិត ។

JOUBERT

**៤៣២-** ស្នេហាច្រើន នាំឱ្យបេះដូងរីកទូលាយ ។

JOUBERT

**៤៣៣-** រៀនតែម្នាក់ឯង វាងកោហើយមិនសូវបែកបញ្ញាទេ ។

**(ពិចារណា)**

**៤៣៤-** គ្មានមិត្តភាពណាដែលមាំមួនជាស្ថាពរទេ បើមិត្តភាពនោះមិនផ្អែកទៅលើឆន្ទៈរួមមួយ ឆន្ទៈខ្ពង់ខ្ពស់ដែលអាចទាក់ទាញព្រលឹងទាំងពីរ ឱ្យកាន់តែបានជិតស្និទ្ធនឹងគ្នាជានិរន្តរ៍ ដោយគតិបណ្ឌិតនឹងសុភវិនិច្ឆ័យ ។

MANWATER

**៤៣៥-** មានមនុស្សច្រើនគ្នាយល់ថា ការទាក់ទងសន្ទនាស្គាល់គ្នា គឺជាបញ្ហាកាមគុណ ម្លោះហើយបានជាគេមានកំហុសច្រើនខាងផ្លូវកាមតណ្ហានៅទីបញ្ចប់ មនុស្សទាំងពីរនាក់នេះត្រូវបែកបាក់ហើយស្អប់គ្នារកទីបំផុតគ្មាន ។

**(ពិចារណា)**

**៤៣៦-** ការទាក់ទងរាប់អានគ្មានមានប្រយោជន៍ដល់យុវជន គឺនាំឱ្យគ្នាបានល្អ ហើយចៀសវាងការផ្ដេសផ្ដាស មានកាមតណ្ហាអូសទាញជាដើម។

ការទាក់ទងរាប់អាននេះមានប្រយោជន៍ដល់មនុស្សចាស់គឺ កាលណាខ្លួនមានជម្ងឺឈឺថ្កាត់ គឺបានការបបោសអង្អែលលួងលោម បានការជួយឧបត្ថម្ភនាំឱ្យការរាប់អានសន្ទនាស្គាល់គ្នា គឺជាប្រការមួយនៃការលួងលោមបោសអង្អែលធំបំផុតនៅក្នុងលោក ។

(ពិចារណា)

**៤៣៧**- មិត្តកុំចោះប្រហោងទ្រនប់ឱ្យទឹកវាហូរ ទោះប្រហោងនោះធំឬតូចក៏ដោយ ដូចគ្នានឹងកុំបណ្ដោយឱ្យស្ត្រីកាចបញ្ចេញអាការៈមកក្រៅដោយសេរីភាព ។ បើស្រីនោះមិនអាចស្ដាប់បង្គាប់មិត្តទេ គឺវានឹងបង្កើតរឿងឱ្យមិត្តអាម៉ាស់មុខដោយសត្រូវរបស់មិត្ត ។

P. FLETRIUS

**៤៣៨**- មិត្តមិនគប្បីប្រគល់វាសនា នឹងព្រលឹងយើងទាំងមូលឱ្យទៅលើអំណាចរបស់មនុស្សស្រីទេ ។

WATERSTONE

**៤៣៩**- មនុស្សអាចធ្វើអ្វីបានទាំងអស់ កាលណាមនុស្សនោះអាចក្លាយទៅជាសត្រូវនៃចរិយាធម៌ នឹង សប្បុរសធម៌ ។

Massillon

**៤៤០**- នៅកន្លែងណាគ្មានសេចក្ដីស្មោះត្រង់យោគយល់ នៅកន្លែងនោះ គឺមានផុកនៅក្នុងផ្ទះ ។

La cordaire

**៤៤១-** ការប្រចណ្ឌ គឺជាជីវិតមួយរស់នៅក្នុងសេចក្ដីសង្ស័យ វាអាចឃោរ-ឃៅឬរលាយបាត់ក្នុងពេល ដែលមនុស្សវាដើរពីសេចក្ដីសង្ស័យទៅការពិត។

**៤៤២-** ការសង្ស័យទៅលើមិត្តភាព គឺជាសេចក្ដីថោកទាបមួយលើសពីសត្រូវគេបោកប្រាសទៅទៀត ។

**៤៤៣-** មិនអាចស្រឡាញ់ជាលើកទីពីរបានទេ នូវប្រការណាដែលយើងបានស្អប់ជាខ្លាំងរួចមកហើយ ។

La Roche Foucauld

**៤៤៤-** នៅកន្លែងណាគ្មានសមភាព នៅកន្លែងនោះគ្មានមិត្តភាពទេ ។

Sully Prudhomme

**៤៤៥-** ក្នុងពេលមានបានគិតឃើញតែពីរឿងផ្ទាល់ខ្លួន ដល់ពេលមានគ្រោះថ្នាក់អ្នកនោះឯងមុខជាឯកាមិនខាន។

Florian

**៤៤៦-** តាមយោបល់ខ្ញុំ គឺខ្ញុំចូលចិត្តសត្រូវដែលនិយាយត្រង់ៗជាជាងមិត្ត-ភក្ដិដែលនិយាយបញ្ជោរលើកជើង ។ Arnault

**៤៤៧-** មិត្តភក្ដិហើយមានការឈឺចាប់ៗតែម្នាក់ឯង គឺជាប្រការមួយនាំឱ្យអាម៉ាស់ដល់មិត្តខ្លួន។ Roton

**៤៤៨-** គំនិតអត្តទត្ថភាពមិនអាចគេចផុតពីសេចក្ដីទុក្ខសោកវេទនាបានឡើយ ។

Goethe

**៤៤៩-** គេមិនអាចធ្វើមានបាន ដោយសារប្រការដែលគេយកបាននោះទេ ផ្ទុយទៅវិញ គឺគេធ្វើមានបានដោយសារប្រការដែលគេឱ្យ ។

J Flory

**៤៥០-** បើមិត្តចង់ឱ្យស្នេហារបស់មិត្តបានឋិតថេរយូរអង្វែង មិត្តគប្បីធ្វើឱ្យបាត់អស់នូវក្លិនកាមតណ្ហា ។ ធម្មតាស្រាតែគេទុកបានយូរគឺស្រានោះល្អ ហើយឆ្ងាញ់ទៀតផង ។

**៤៥១-** ទឹកកខ្វក់មួយស្លាបព្រា អាចនាំឱ្យខូចទឹកស្អាតមួយពាងផ្ទុយទៅវិញ ទឹកស្អាតមួយពាងមិនអាចនាំឱ្យទឹកកខ្វក់មួយស្លាបព្រាស្អាតបានទេ។

**(បទពិចារណា)**

**៤៥២-** គូដណ្ដឹងស្រឡាញ់ប្រពន្ធខ្លួន យ៉ាងស្មោះស្ម័គ្រមិនមែនគ្រាន់តែស្រឡាញ់ខ្លួនប្រាណ គំនិតមារយាទប៉ុណ្ណោះទេ គឺស្រឡាញ់ភាពនៅក្មេងថែមទៀត ព្រមទាំងស្រឡាញ់នូវភាពទន់ខ្សោយដើម្បីជួយការពារ ស្រឡា-ញ់ ភាពផ្អែមល្ហែមដើម្បីប្រមូលយក ។

P. duboyer

**៤៥៣-** នោះគឺជាមនុស្ស ដែលខ្ញុំអាចប្រគល់ឱ្យនូវកិច្ចការធំដុំ មកអំពី

មនុស្សនោះមានលក្ខណៈជ័យជំនះ៣យ៉ាងគឺ ជំនឿ គោរព នឹងជាទីពឹង ៣ក់ ។

De Vogue

**៤៥៤**- មិត្តចង់ឱ្យខ្ញុំស្ងួង់ ឬ ទាយនូវសេចក្ដីស្នេហារបស់មិត្តត្រូវឬទេ ? សុំមិត្តនិយាយឱ្យស្ដាប់មើល តើវានាំឱ្យមិត្តមានវិបត្តិឬទេ ?

Garcot

**៤៥៥**- ខ្ញុំគ្មានមិត្តសម្លាញ់ឯណាទៀតទេ ក្រៅពីមិត្តដែលដឹកនាំខ្ញុំឱ្យឡើងទៅដល់លើកំពូលតែក្នុងមួយសន្ទុះ ។

F. Chermont

**៤៥៦**- ខ្ញុំចង់ធ្វើឱ្យមិត្តសប្បាយចិត្ត ប៉ុន្តែខ្ញុំចង់ជួយសង្គ្រោះមិត្តច្រើនជាង។

Caton

**៤៥៧**- ឧត្តមគតិនៃសេចក្ដីស្នេហាស្និទ្ធស្នាល គឺ (យល់ឃើញ១) តែវានៅ (តែពីរ) ។

Mme Swet chine

**៤៥៨**- ទៅខ្វល់អ្វីនឹងសេចក្ដីស្នេហាមុនដំបូងដែលវានាំឱ្យ យើងកង្វល់ចិត្ត ។

Gresset

៤៥៩- យ៉ាងម៉េច? មិត្តគ្មានសេចក្តីស្នេហាហើយមិត្តឆ្លើយថា : មិត្តមានជីវិតរស់នៅឬ ?
A de Musset

៤៦០- ស្រឡាញ់កាន់តែច្រើន ហើយបោះចោលទៅ គឺកាន់តែសប្បាយ។
La fontaine

៤៦១- ស្រឡាញ់គឺជាភាគពាក់កណ្តាលនៃសតិអារម្មណ៍។
Victor Hugo

៤៦២- ក្នុងពេលដែលព្រះអាទិទេព បង្កើតបេះដូងមនុស្សលោកបានបង្កើតមុនដំបូងបង្អស់នូវចិត្តមេត្តា ។
Bossuet

៤៦៣- ប្រការដែលខ្ញុំទទួលស្គាល់យ៉ាងជ្រៅជ្រះ ថាជាការរាប់អានស្និទ្ធស្នាលនោះ គឺមានរវាងតែមនុស្សត្រឹមត្រូវទេ ។
Ciceron

៤៦៤- មិត្តភាពគឺជាសប្បុរសធម៌ទៅវិញទៅមក ដែលវាលេចឡើងដោយលទ្ធផល ។ St. Thomas d'Aquin

៤៦៥- បើអ្នកណាមិនយល់អស់នូវបញ្ហាសាច់ឈាមទេ អ្នកនោះឯងនឹងត្រូវសាច់ឈាមវាអូសទាញយ៉ាងខ្លោចផ្សា ។ St. Auguotin

**៤៦៦**- នៅក្នុងបណ្តាតណ្ហាទាំងឡាយ មានតែកាមតណ្ហាទេដែលខ្លាំងជាងគេ ពីព្រោះវាជ្រែកស្ទើរតែអស់ខួរក្បាលយើងវា ជ្រែកអស់បេះដូងនឹងខ្លួនប្រាណយើង ។

**៤៦៧**- ស្នេហាបង្រួបបង្រួមប្រុសស្រី គឺជាមនោសញ្ចេតនាមួយបែបយ៉ាងស្មុកស្មាញ នៅក្នុងនោះរួមមានសមត្ថភាពនៃបញ្ញា សមត្ថភាពបេះដូងនឹងចរិតនៃសត្វលិ្វតល្វង់ ។

Carnot

**៤៦៨**- សេចក្តីរាប់អានស្និទ្ធស្នាល បើចង់ឱ្យមានប្រយោជន៍ត្រូវឱ្យមានលក្ខណៈថ្លៃថ្នូរខ្ពង់ខ្ពស់ ។

**៤៧៩**- ខ្ញុំឃើញសេចក្តីរាប់អានស្និទ្ធស្នាល ដូចជាគុវង្វាន់មួយយ៉ាងមានតម្លៃ ដែលទេព្តាបានផ្តល់ឱ្យយើងទាំងអស់គ្នា ។

Ciceron

**៤៨០**- សេចក្តីស្នេហាដែលគេមានចំពោះអ្នកណាមួយ បើគ្មានការបបោសអង្អែលសម្រើបសម្រាលទេ វាគ្រាន់តែជាមិត្តភាពប៉ុណ្ណោះ វាមិនមែនជាសេចក្តីស្នេហាឡើយ ។

P. Segur

**៤៨១**- តម្លៃនៃសេចក្តីស្នេហា វាផ្អែកទៅលើតម្លៃទាំងមូលនៃខ្លួនមនុស្ស។

Gusiave Thibon

**៤៨២-** គឺការរាប់អានស្និទ្ធស្នាលនេះហើយ ដែលនាំឱ្យយើងសប្បាយរីករាយយ៉ាងខ្លាំង រហូតដល់ទៅ បើគ្មានទេប្រការដែលនាំឱ្យយើងសប្បាយចិត្តទៅជាធុញទ្រាន់ បើមានវា ការលំបាកទាំងអស់នឹងក្លាយទៅជាធូរស្រាល។

St. THOMAS D'AQUIN

**៤៨៣-** ការរាប់អានស្និទ្ធស្នាល គឺជាព្រលឹងមួយនៅក្នុងខ្លួនពីរ។

Pythagore

**៤៨៤-** ប្រចណ្ឌចេះគឺបង្ហាញនូវសេចក្តីស្នេហាភ្លឺស្វាង វាងវៃហើយអះអាងបាននូវសុភមង្គលគ្រួសារ ។ បើប្រចណ្ឌលង្វង់គឺជារបៀបមួយនាំឱ្យបាត់គូស្នេហា ហើយនាំឱ្យគ្រួសារចង្រៃរោរព។

Francois Richel

**៤៨៥-** មិត្តស្និទ្ធស្នាលគឺមនុស្សបម្រើមិត្តមួយរយដង ហើយចង់បានផលតែម្តងទេ ។

Mme Swetchine

**៤៨៦-** មិត្តភាពដូចរទេះឡានតាក់ស៊ី គេមិនអាចជួបវាបានទេនៅពេលមានភ្លៀងផ្គរ ។ P Bonnet

**៤៨៧-** ស្រឡាញ់មិនមែនរកចំណេញទេ គឺដើម្បីរកធម៌សប្បុរស ។

Sertillauges

៤៨៨- ស្នេហាគឺជាការសប្បាយ តែកិត្តិយសគឺជាភារៈកិច្ច។
P. Corneille

៤៨៩- ស្នេហា (ឱ! ធម្មជាតិចំឡែកនៃការបោកប្រាស់អើយ) ឯងរស់នៅបានដោយសារស្រេកឃ្លាន តែឯងត្រូវស្លាប់ដោយសារឆ្អែតឆ្អន់។
De Musset

៤៩០- មិត្តភាពគឺជាឪពុកម្ដាយ ដែលមនុស្សបង្កើតវាសម្រាប់ឱ្យមនុស្ស។
Emile Deschamps

៤៩១- ស្នេហាវាមានសម្រើបស្រើបស្រាល ដូចគ្នានឹងទុក្ខវេទនារបស់វា។
La Fontaine

៤៩២- សេចក្ដីស្នេហារាប់អាននៃមនុស្សខ្ពង់ខ្ពស់ គឺជាសគុណមួយរបស់ទេព្ដា ។ Voltair

៤៩៣- ពីរភាគបីនៃការរស់នៅខាងផ្លូវចិត្តនឹងការចលនា នៃជីវិតមនុស្សទាំងអស់គ្នា វាវិលវង្សនៅជុំវិញរឿងស្នេហា ។ ចំពោះបញ្ហាស្នេហានេះមានមនុស្សយល់វាខុសគ្នាច្រើនណាស់ ។ Tracjanus

៤៩៤- គ្មានស្នេហាណា ដែលមិនទាក់ទងទៅនឹងសាច់ឈាមនោះទេ ព្រោះស្នេហាវាត្រាយផ្លូវឱ្យកាមតណ្ហា ។
Kergalard

៤៩៥- មនុស្សស្រី ធម្មជាតិបង្កើតឡើងមុនបង្អស់ គឺដើម្បីស្រឡាញ់ដើម្បី ចលនាធ្វើប្រពន្ធគេនឹងធ្វើម្តាយ ។

P. gillet

៤៩៦- សេចក្តីស្រឡាញ់រាប់អានគ្នាដែលគួរឱ្យគោរព គឺជាការជួយឧបត្ថម្ភមួយ សំរាប់ពិចារណាសេចក្តីសប្បុរស ជាជាងលុយកាក់ ប្រាក់មាស ជាជាងកិត្តិយសទៅទៀត។

St. Ambroise

៤៩៧- កាលពីក្មេង មានស្រីប្រុសជាច្រើនបានយល់ថាស្នេហាគឺជាល្បែងលេង។ ដល់មិនប្រុងប្រយ័ត្នពួកគេត្រូវ (ល្បែងលេង) ដ៏គ្រោះថ្នាក់នោះធ្វើបាបគេយ៉ាងឈឺចាប់។

R. Casimir

៤៩៨- ដោយសារការរាប់អានសំណើសសំណាលនេះហើយដែល មនុស្សត្រូវបែកបាក់ព្រាត់ប្រាស់គ្នាបានធូស្រាល មនុស្សឈឺបានលួងលោមបបោសអង្អែល ហើយប្រការនេះវាកាន់តែពិបាកទៅទៀត គឺមនុស្សដែលស្លាប់បាត់ទៅហើយ បានរស់បន្តទៅទៀត ។

Ciceron

៤៩៩- ស្នេហាមិត្តភាពនាំឱ្យចម្រើនលូតលាស់បានល្អ គំនុំគំគួនត្រូវអន់ថយមកអំពីវារួបរួមនូវសេចក្តីសប្បាយនិងសេចក្តីទុក្ខ។

Z . sidore

៤៩០- មានសុភមង្គលណាធំឱ្យស្មើនិងសុភមង្គលបានជួបមនុស្ស ម្នាក់ ដែលក្នុងចិត្តថ្លើមមនុស្សនោះ យើងអាចវែកបង្ហាញបាននូវចំណុចសម្ងាត់ទាំងអស់ ជឿជាក់ទៅលើពាក្យសម្ដីប្រយែងប្រយ័ត្នរបស់គេជាជាងរបស់យើង ។

Seneque

៤៩១- ការសន្ទនារាប់អាន គឺជាការជួយគ្នា គឺជាតុរង្វាន់មួយហើយក៏ជាខ្សែចងដែរ ។ L . Veuillot

៤៩២- អ្នកក្រមានមិត្តភក្តិតិចណាស់ តែបើបានជួបម្នាក់គឺសប្បាយជាទីបំផុត ។ Z . Sarto

៤៩៣- មិត្តក្នុងការរាប់អានសន្ទនាគ្នា អាចជួយមិត្តឱ្យបានជ័យជម្នះនៅក្នុងជីវិតគឺជាមនុស្សរួមសុខទុក្ខគិតដល់មិត្តជាមួយគ្នា មានឧត្តមគតិដូចគ្នា ហើយជាពិសេសមានបញ្ញាវាងវៃក្នុងការអនុវត្តន៍ឧត្តមគតិនោះជាមួយ នឹងមិត្ត។ ពីព្រោះហេតុនោះ មិត្តកុំសន្និដ្ឋានតែទៅលើគេជួយយកអាសាមិត្ត តែត្រូវសំដៅទៅលើគេជួយធ្វើសហប្រតិបត្តិការដើម្បីបម្រើសុភមង្គល របស់មិត្តនឹងគេ ។ Manwater

៤៩៤- គ្មានមនុស្សណាពូកែគ្រប់មុខតែម្នាក់ឯងបានទេ ដូច្នេះក្នុងពេលធ្វើការធំដុំគេត្រូវមានសហប្រតិបត្តិការជាចាំបាច់ មិត្តសន្ទនារាប់អានគ្នា គឺជាអ្នករួមកម្លាំងយ៉ាងពូកែមួយដើម្បីទៅដល់ជ័យជម្នះ។

Marcel Zone

**៤៩៥-** វត្ថុបំណងធំបំផុតនៃស្នេហា គឺអាពាហ៍ពិពាហ៍ វត្ថុបំណងធំបំផុតនៃអាពាហ៍ពិពាហ៍គឺបន្តកូនចៅ បង្កើតសុភមង្គលគ្រួសារ ប្តីប្រពន្ធត្រូវរួមកម្លាំងគ្នា ធ្វើអំពើណាដែលមានប្រយោជន៍ដល់សង្គម។

Germaine

**៤៩៦-** វត្ថុបំណងនៃការសន្ទនារាប់អានគ្នា គឺដើម្បីបង្កើតនូវជីវភាពភ្លោះមួយ ដើម្បីទ្រាំទ្រនឹងទុក្ខវេទនានៅក្នុងវដ្តសង្សារ ដើម្បីសម្រេចកិច្ចការធំដុំ។

Jeans Cellet

**៤៩៧-** ក្នុងជីវិតប្តីប្រពន្ធ បើគេពិនិត្យផ្នែកខាងចរិយាធម៌ គេឃើញមានប្រការបោកប្រាស់ភូតភរច្រើនណាស់ ប្រការឆ្លៀតឱកាសគ្នាទៅវិញទៅមក ជាពិសេសគឺនៅពេល ដែលអ្នកទាំងសង្ខាងនៅក្មេងងាយធ្វើបាវព្រាវសេចក្តីស្នេហា ។

H . Benediciton

★ ★ ★

**ចប់**